ទស្សនាវដ្ដី លេខ ១០

# ពុទ្ធិកវិទ្យាល័យ



ទីចាត់ការ វត្តលង្កា សង្កាត់លេខ ៦
ភ្នំពេញ

ពាងប្រាង. ចណ្ណាភិការ. ហួតតៀប

Don Offert par M. IMPRIMERIE VIRIYA PPENH

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ | វិចារណកថា | ទំព័រទី | ១ |
| | ដំណើរសាសនា | ,, | ៣ |
| មហា ថោង-ទិត | ស្ថានការណ៍នៅសហភាពភូមា | ,, | ៧ |
| ភិក្ខុ អាំ-សួន (ហៅ ហម) | សាសនាជេន នឹងពុទ្ធសាសនា | ,, | ១៥ |
| ភិក្ខុ លី-គឹមឡុង | ពិធីបុណ្យឆ្លងឆដ្ឋសង្គាយនា | ,, | ២០ |
| ព្រះពុទ្ធវង្ស កៅ-ស៊ឹម | បុរាណនិវេសន៍ | ,, | ២៤ |
| ព្រះគ្រូបវរត្តិមវាលី អ៊ូ-ប៉េវ | ធនញ្ជយបណ្ឌិត | ,, | ២៨ |
| លោក តែ-ជុន | ជ័យប្រាជ្ញ (ត) | ,, | ៣២ |
| | ពាក្យថ្មីរបស់គណកម្មការវប្បធម៌ | ,, | ៣៧ |
| ភិក្ខុ អាំ-សួន (ហៅ ហម) | របនាវិលាសវាក្យភាសាអង់គ្លេស | ,, | ៣៨ |


## ថ្លៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលជាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-មុី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

## សេចក្ដីជូនដំណឹង

សូមព្រះថេរានុត្ថេរៈនិងអស់លោក-អ្នក-មិត្តទាំងឡាយ ដែលបានជាវទស្សនាវដ្ដីនេះ ហើយពុំទាន់បានបង់តម្លៃជាវនៅឡើយនោះ សូមទានមេត្តាផ្ញើបច្ច័យប្រាក់ទៅបង់តម្លៃឲ្យទានដោយអនុគ្គហភាព ៗ ព្រោះពលភាពនៃថវិកាសម្រាប់ចំណាយបោះពុម្ពនោះ កាន់តែខ្សត់ខ្សោយណាស់ទៅហើយ ៗ

សូមព្រះថេរានុត្ថេរៈនិងអស់លោក-អ្នក-មិត្តទាំងឡាយ មេត្តាជួយឧបត្ថម្ភទំនុកបំរុងជីវភាពនៃទស្សនាវដ្ដីនេះឲ្យមានពលភាព-វឌ្ឍនភាពជាស្ថាពរតទៅឲ្យទានផង ។ ៗ

សូមអរគុណទុកជាមុនដ៏ជ្រាលជ្រៅដោយសេចក្ដីស្មោះស្ម័គ្រ ។ ៗ

# វិចារណកថា

## ជំហានអក្សរសាស្ត្រជាតិ

គេដឹងហើយថា កាលបរិច្ឆេទនៃការប្រើអក្សរសាស្ត្រជាតិតាមផ្លូវការបានកន្លងផុតមក ១ខែហើយ តើលទ្ធផលនោះចំរើនដល់ណា ?

ចំពោះរឿងនេះយើងមិនបាច់ពណ៌នាឲ្យវែងឆ្ងាយពេកទេព្រោះគ្រប់តែសារពត៌មានខ្មែរទូទៅក៏បានចោទចំលើយបញ្ហាអក្សរសាស្ត្រនេះដែរ តាំងពីកាលវេលាមិនទាន់មកដល់ម៉្លេះ ៗ ប៉ុន្តែមតិអ្នកអានទាំងអ្នកនិពន្ធ ដូចជាមិនទាន់វេញបញ្ចូលផ្តុំគ្នានៅឡើយ ដោយហេតុតែជនជាតិយើងពេញចិត្តយករឿងផ្ទាល់ខ្លួនមកចោទលាយជាមួយផង ៗ

ដើម្បីឲ្យងាយដោះស្រាយបញ្ហាអក្សរសាស្ត្រជាតិ ត្រូវយើងយកខ្មែរណាដែលយល់ច្បាស់នូវបញ្ហាជាតិ និងសេចក្តីសម្រេចនៃសមាជជាតិលើកទី១ និងមតិគណៈកម្មការវប្បធម៌ មកធ្វើជាបាទនៃបញ្ហានោះទើបអាចដោះស្រាយបាន ៗ បើសិនណាជាយើងចេះតែបណ្តោយហើយមិនបានបន្ទឹងគំនិតរឿងនេះទេ ល្បឿននៃអក្សរសាស្ត្រជាតិពិតជាមិនលឿនទៅមុខឡើយ; ការបន្ទឹងគំនិតដំណើរអក្សរសាស្ត្រនឹងកើតឡើងបានក៏អាស្រ័យឥស្សរៈជនទូទៅក្នុងព្រះរាជណាចក្រ ដែលនៅក្នុងដំណែងជានាយកនៃការិយាល័យនីមួយ ៗ ហើយត្រូវការចាប់ផ្តើមប្រតិបត្តិពីឥស្សរៈជននោះ ៗ ផង ៗ

ខ្ញុំតែងឮពាក្យពោលដំពាស់ដែលមិនសមហេតុផលជាច្រើនដូចជាថា „មិនទាន់មានប្រកាសចេញបង្គាប់, ខ្វះអង្គុលីលេខប្រើ, ធ្វើការយឺតជាដើម„ ពាក្យប៉ុណ្ណេះនេះក៏មិនសមនឹងឲ្យឮដល់ត្រចៀកគេឯងឡើយ ៗ មួយវិញទៀត ឃើញថាខ្វះការទម្លាប់

មួយ យ៉ាងសំខាន់គឺដូចជាការលើលិខិតសម្រាប់បង្គាប់ទៅលើបុគ្គលិកតូចតាចក៏ដោយ ក៏គង់នៅចូលចិត្តការអក្សរបរទេសដែរ ទម្លាប់នេះមិនគួរសោះ បើយើងសរសេរគ្រាន់តែឲ្យគ្នាយើងមើលប៉ុណ្ណោះម្តេចក៏តាំងសរសេរជាអក្សរបរទេសដែរ ។ ប្រកាសក្រសួងក្តីព្រះរាជក្រិត្យព្រះរាជក្រមក្តីដែលធ្វើឡើងជាអក្សរបរទេសក៏រឹតតែការច្រើនណាស់ទៅទៀត ចុះទាស់អ្វី? បើយើងគ្រាន់តែសរសេរជាអក្សរជាតិម្តងទៅមិនបានចុះ? ដូចជាបទបញ្ជាខ្លះដែលសំរាប់ប្រើក្នុងប្រទេសយើងក៏ដោយ ក៏នៅតែឆ្លៀតសរសេរអក្សរបរទេសផងដែរ ហើយបើគេសួរដេញដោលទៅថា អក្សរគេមានរបៀបបែបផែនត្រឹមត្រូវពិតប្រាកដជាងអក្សរជាតិយើង ខ្លះទៀតថាមើលអក្សរខ្មែរពុំសូវយល់ទេ បើមើលអក្សរបរទេសវិញនោះទើបបានយល់„ ។ ពាក្យនេះសូមខ្មែរកុំបបួលគ្នានិយាយឲ្យសោះ បើជាតិដទៃគេឮមុខតែសើចទឹងយើងរយះមាត់មិនខានឡើយ; មិនដែលមានបើខ្លួនជាខ្មែរហើយស្តាប់ខ្មែរមិនយល់នោះ ចុះឲ្យជាតិណាទៅវិញគេយល់ខ្មែរជាងខ្មែរយើងបាន ?

អើយើងគួរដឹងខ្លួនខ្លះទៅថា បើខ្មែរមិនព្រមរៀនខ្មែរមិនព្រមយល់ខ្មែរ តើទុកឲ្យនរណាគេរៀនខ្មែរហើយយល់ខ្មែរជំនួសខ្មែរទៅវិញ រឿងនេះគេមុខតែគេចោទយើងថាជាន់ខ្មែរពន្លិចទៅរកគេប្រោះប្រៅទៀតហើយ ។

បណ្ណាធិការ

# ដំណឹងសាសនា

(គ)

លោក-អ្នក បព្វជិតគ្រហស្ថទាំងឡាយ !

កាលព.ស. ២៤៨៧ គ.ស. ១៩៤៣ កន្លងទៅហើយ ជាកាលកំណើតរោគដែលចាប់កើតជាលើកដំបូងក្នុងករដកាយរបស់ខ្ញុំករុណា អាត្មា សំដែងអាការកំទៀហួសហេតុ បានបញ្ចេញកំណាចកាចឃោរឃៅដូចអាសិរពិស ចាប់ឈឺពេតចាក់រុករោលក្នុងអង្គកាយនេះស្ទើរតែអត់ទ្រាំពុំបាន តែដោយអំណាចតេជានុភាពសម្តេចព្រះមហាក្សត្រិយានី មានព្រះសុវណ្ណី បញ្ជាឲ្យលោកគ្រូពេទ្យនាម អេម មកព្យាបាលជាលើកដំបូង ប្រឆាំងទប់ទល់នឹងរោគនេះជារាល់ថ្ងៃ, បន្ទាប់មកបានយកលោកគ្រូពេទ្យ (Docteur) ផ្កាស៊ី មកប្រយុទ្ធនឹងរោគនេះទៀតក៏បានជាស្បើយគ្រាន់បើរហូតមកដល់ ព.ស. ២៤៩៩គ.ស. ១៩៥៦, រោគនេះក៏រើរើជាថ្មីឡើងវិញ ក៏បានយកលោកគ្រូពេទ្យ (Docteur) ដួន-ដឿន នឹងលោក លាន-ស៊ាន មកព្យាបាលប្រយុទ្ធនឹងរោគដដែលនេះថែមទៀត ទាល់តែរោគនេះសាបរលាបខ្សោយកម្លាំងទៅ នាំឲ្យខ្ញុំករុណា អាត្មា មានខ្យល់អស្សាសបស្សាសដើរធូរស្រួលឡើងជាដរាប ។

ឱកាសនេះអស់លោក-អ្នក ដែលជាក្រុមបព្វជិត ឧបាស-សិកា ទាំងឡាយ ដែលមានសេចក្តីស្នេហាចំពោះខ្ញុំករុណា អាត្មា បានមូលមតិស្របគ្នា ធ្វើបុណ្យកតញ្ញូជាកុសល ដើម្បីតបបដិការគុណឧទ្ទិសប្រគេនចំពោះខ្ញុំករុណា អាត្មា ។ មានសេចក្តីត្រេកអរជា

ភិយ្យោភាព ហើយបានតាំងសតិធ្វើមនសិការៈប្រកបដោយមានោសញ្ចេតនា ធ្វើបដិគ្គហណកិច្ចទទួលយកកុសលនេះ ដែលជាឧបការគុណដ៏បរិសុទ្ធរបស់អស់លោក-អ្នក ដែលបានប្រសិទ្ធជាបុញ្ញប្យតាប្រកបដោយសោមនស្សជ្រះថ្លា ប្រគេនចំពោះខ្ញុំករុណាអាត្មា សូមកុសលនេះឧបត្ថម្ភជួយជាកម្លាំងបណ្ដេញរោគាពាធ ដែលមានក្នុងអង្គកាយរបស់ខ្ញុំករុណា អាត្មា ឲ្យរលាយបាត់ខ្ចាត់ខ្ចាយចេញពីសរីរៈ តាំងពីថ្ងៃនេះតរៀងទៅ ដោយអំណាចបុណ្យកតញ្ញូរបស់អស់លោក-អ្នក ដែលបានប្រសិទ្ធដោយសុទ្ធចិត្តដ៏ស្អាតប្រគេនចំពោះខ្ញុំករុណា អាត្មា ៗ បានធ្វើអាយាចនវាចាបួងសួងដោយស័ក្តិសិទ្ធិនេះ សូមឲ្យសម្រេចសេចក្ដីប្រាថ្នាជាខាងក្រោយបង្ហើយកិច្ចបុណ្យកតញ្ញូតែប៉ុណ្ណេះ ៗ

បន្ទាប់អំពីនេះទៅ ខ្ញុំករុណា អាត្មា សូមលើកកុសលដែលកើតអំពីបុណ្យកតញ្ញូរបស់អស់លោក-អ្នក ដែលបានប្រគេន ខ្ញុំករុណា អាត្មានេះ ថ្វាយជាព្រះរាជពលីចំពោះព្រះករុណាជាម្ចាស់ជីវិត, សម្ដេចព្រះមហាក្សត្រិយានី, សម្ដេចព្រះឧបយុរាជ សូមទ្រង់ស្ថិតនៅក្នុងសិរីរាជសម្បត្តិ ប្រកបដោយសុខសួស្ដីជ័យមង្គលគ្រប់ប្រការអស់កាលជាអង្វែងតទៅ ៗ

សូមឧទ្ទិសភាគផលនេះ ជូនចំពោះទេវបុត្រ ទេវតា មារ ព្រហ្ម យមយក្ស អារុក្ស អារក្ស ទេព្រក្ស និងមនុស្សទាំងឡាយ ព្រមទាំងសត្វទ្វេបាទ ចតុប្បាទ ពហុប្បាទ សូមទទួលយកដោយសញ្ញា ហើយសូមឲ្យមានអាយុយឺនយូរអស់កាលដ៏ឡូង ៗ

សូមឧទ្ទិសភាគផលនេះ ជូនចំពោះក្រុមសិស្សានុសិស្សបព្វជិតគ្រហស្ថឧបាសកសិកាទាំងឡាយ ដែលជាអ្នកខ្វល់ខ្វាយធ្វើបុណ្យកតញ្ញូផ្ទាល់ខ្លួនជូនចំពោះខ្ញុំករុណាអាត្មាដែលជាគ្រូបាធ្យាយរបស់អស់លោក-អ្នក សូមលោកអ្នកទាំងនេះបានមូលមិត្រមួល

*សំឡាញ់ មូលក្រុមគ្រួសារ កុំឲ្យបែកបាក់ចាកគ្នា កុំឲ្យមានរោគាទាំងពួងបៀតបៀន ប្រាសចាកទុក្ខភ័យឧបទ្រពចង្រៃគ្រប់យ៉ាង សូមឲ្យបានប្រកបដោយសេចក្ដីសុខចំរើន មានទីឃាយុយឺនយូរ ទាំងសូមឲ្យមានសាមគ្គីសស្មោះសរគ្នា កុំឲ្យមានពៀរវេរ នឹងគ្នាអស់កាលជានិរន្តរ៍បូរចំរើនក្នុងព្រះពុទ្ធសាសនាតរៀងទៅកុំបីឃ្លាតឡើយ ។*

*ទីបំផុតនៃសំរេចប្រកាសរបស់សម្ដេចនេះ ខ្ញុំព្រះករុណាអាត្មាភាពសូមបួងសួង ដោយមេត្តាករុណាចិត្ត ចំពោះសម្ដេចផង ចំពោះពុទ្ធបរិស័ទទាំងអស់ផង ជាគាថា បាលីដោយសង្ខេបថា.*

អម្ហាកំ សម្ដេចព្រះធម្មលិខិត ឧត្តមប្រឹក្សា មហាបរិវស្ស រោគា តត្ថ នានាពាធគិលានាយ វិហេឋយន្តា អម្ហាកំ កតញ្ញុតានភាវេន តតោ បដ្ឋាយ មា អហេសុំ វិនស្សន្តុ អសេសតោ ។

ពុទ្ធវង្សេ នាម អហម្បន សព្វស្មឹ លង្ការាមេ វសន្តានំ ភិក្ខុសាមណេរានំ ឧបាសកឧបាសិកានញ្ច សាមគ្គីករណត្ថាយ ឥទំ វិប នមព្រឹ, សព្វេ តុម្ហេ មហាបុញ្ញា មហាបញ្ញា មហព្វលា មហាភោគា មហាយសា មហានុភាវា សព្វធម្មេសុ ឋិតា សព្វធរា ពុទ្ធសាសនមាមកា សីលវន្តោ ជិនានម្បិយា សមគ្គា ហោថ សព្វេ តុម្ហេ អញ្ញមញ្ញាវិរោធិនោ, ឥទំ សព្វំ លង្ការាមំ នាម ឋានំ អញ្ញំ អនុ ឯវ មា វិសុំ ហោតុ មេត្តាយោគេកសម្ពន្ធំ សុខំ បវត្តុ ។

តេ តេ ភិក្ខុសាមណេរាទយោ អវិវាទា អកលហា អភិន្នា

សម្មា សមគ្គា សាធុកំ សម្បដិច្ឆិត្វា ពុទ្ធសាសនំ ធម្មវិនយសម្បន្នំ រក្ខន្តុ ចិរំ តិដ្ឋន្តុ សកសកអារាមេសុ ច សកសកាចរិយគណេសុ ច សកសកគេហដ្ឋានេសុ ច សុវត្ថិភាវេន សព្វទា(១) ។

នាកាលសុន្ទរកថារបស់លោកសាស្ត្រាចារ្យឈឹម-ស៊ុម និងសង្វេគប្បកាសរបស់ព្រះតេជព្រះគុណព្រះពុទ្ធវង្សចប់ហើយ, ព្រះមហាថេរទាំង១០អង្គ ក៏ចាប់ស្វាធ្យាយធម៌ជយន្តោ និងធម៌ជាពរឯទៀតខ្លះទៀត ជាកិច្ចប្រសិទ្ធិអាយុវឌ្ឍនមង្គលប្រគេនចំពោះសម្តេច ។ ជាបន្ទាប់នោះ, សម្តេចព្រះមហាសុមេធាធិបតី, ក្នុងចំណោមព្រះថេរទាំង១០អង្គ, បានបួងសួងសូមឱ្យសម្តេចព្រះធម្មលិខិតសះស្បើយចាករោគាពាធជាលំដាប់តាំងពីពេលនេះទៅ ដើម្បីបានជាម្លប់នឹងជាទីគោរពរបស់ពុទ្ធសាសនិកទាំងឡាយ, ព្រះពុទ្ធដីកាសម្តេចជ្រៅទៅទៀតថា "យើងមិនអន្ទូរទេ ចំពោះអាការរោគព្រោះយើងបានដឹងថា រូបកាយសព្វសត្វសុទ្ធសឹងតែជាសម្បុករោគ សុទ្ធតែបែកធ្លាយទៅវិញជាធម្មតាហើយ យើងមិនអន្ទូរទេចំពោះអាការរោគ ព្រោះយើងដឹងថា រូបកាយសត្វទូទៅសុទ្ធតែជាលំនៅរោគ សុទ្ធតែបែកធ្លាយទៅវិញជាធម្មតា ប៉ុន្តែយើងសូមអន្ទូរចំពោះគុណធម៌ប៉ុណ្ណោះ ដើម្បីឱ្យជួយកំចាត់រោគាពាធ ហើយជួយទ្រទ្រង់សម្តេចឱ្យមានកម្លាំងពលំតទៅទៀត ។ ឯព្រះតេជព្រះគុណព្រះពោធិវង្ស ក៏បានបួងសួងសូមឱ្យសម្តេចមានព្រះកាយពលឡើងវិញដែរ ដើម្បីនឹងជួយទ្រព្រះពុទ្ធសាសនាទៅអនាគតទៀត ។

(នៅមានត)

១– សង្វេគប្បកាស ដែលព្រះតេជព្រះគុណព្រះពុទ្ធវង្សរចនាឡើងនេះដោយគណៈកម្មការវត្តលង្កា តម្រូវឱ្យធ្វើតាមសមគួរដល់ការសូត្រជាតំណាងសម្តេច ទទួលអំណរចំពោះសិស្សគណទាំងអស់ ក្នុងពេលធ្វើបុណ្យកតញ្ញូ ។

# ស្ថានការណ៍នៅសហភាពភូមា(តនឹងចប់)

បំណែកស្ត្រីបង្រៀនឲ្យចេះត្បាញ ចេះវៃ ដេរប៉ាក់ ប៉ះស៊ប៉ុនបំណះដាច់ដាច បាន ដូចគ្នានឹងស្ត្រីអ្នកជា ហើយគ្រាន់បើជាជាងស្ត្រីអ្នកជា ដែលល្ងង់ខ្លៅប្រហូសពុំប្រកបការងារផ្សេងៗ ។ បំណែកខាងបុរស បង្រៀនឲ្យចេះអានសរសេរអក្សរ ឬក៏ត្បាញល្អី អង្រឹងជាដើម ប្រហែលគ្នានឹងបុរសដែលអ្នកជា តែគ្រាន់បើជាបុរសអ្នកជាល្ងង់ខ្លៅ ខ្លៅប្រហូស ពុំបានរវាសរវៃប្រកបកិច្ចការផ្សេងៗទៅទៀត ។ គួរបើដែរ បុរសស្ត្រី ដែលអន្ធការ ក្អែកខ្វាក់សោះ រដ្ឋាភិបាលគេចេះតែខំឲ្យបានការទៅជាមនុស្សមានប្រ-យោជន៍ មានការងារធ្វើប្រហែលគ្នានឹងមនុស្សសាមញ្ញដែរ ។ ដូច្នេះគួរគិតថា កិច្ចការក្នុងលោកមិនហួសវិស័យនៃមនុស្សក្នុងលោកទេ គ្មានអ្វីឲ្យកែជាជាងសេចក្តីព្យា-យាមធ្វើ ព្យាយាមគិត-សន្សំត្រិះរិះពិចារណានោះទេ ។

១ ទៀត គេមានបង្កើតសមាគមការអប់រំសីលធម៌អារ្យធម៌ ដល់ពួកកុមារ-កុមារីទាំងឡាយ គឺបង្ហាត់បង្រៀនកុមារនឹងកុមារី ឲ្យចេះថ្លែងការណ៍ទូន្មានប្រៀនប្រដៅ នឹងដាស់តឿនក្រើនរំឭកគ្នា ដោយពាក្យជាអាទិថា ហៃកុមារទាំងឡាយ! យើងជាកុមារពិត តែយើងជាពលរដ្ឋនៃប្រទេសដែរ, យើងត្រូវនាំគ្នាសិក្សាបំណះវិជ្ជា-ផ្សេងៗ ទាន់ខ្លួននៅក្មេង, យើងត្រូវពួតដៃគ្នាកសាងជាតិ មាតុប្រទេស, អំណើះអំពីបិតាយើងទៅ យើងហ្នឹងឯងហើយជាចង្កូតនៃប្រទេស, នាំគ្នាការពារសត្រូវដែលប៉ងបៀតបៀនយើង, យើងត្រូវរក្សាសាមគ្គីរវាងជាតិយើង! ដូច្នេះជាដើម ។ បំណែកកុមារីក៏មានការអប់រំយ៉ាងនេះដែរ ម្ល៉ោះហើយកុមារ-កុមារីទាំងឡាយ ឃើញឮដឹងជាក់នូវស្ថានការណ៍បែបនេះហើយ យូរៗទៅគង់ភ្ញាក់ស្មារតី ប្រែគំនិតប្រាជ្ញា

លះបង់នូវអំពើឃោរឃៅ កំនិតរ៉ុលរបួចខឹលខូចបន្តិចម្តងៗ ដោយសារដម្បូន្មានក្នុងៗ សម្បាលគ្នាខ្លះ អំពីសំណាក់គ្រូអាចារ្យខ្លះ អំពីបិតាមាតាខ្លះ អស់ទយកាលយ៉ាងនេះ គង់ក្លាយទៅជាមនុស្សត្រឹមត្រូវ មនុស្សបានការពុំខាន ទាំងជាហេតុនាំឲ្យបំរើន សតិបញ្ញា នឹងមានសមត្ថភាព សេចក្តីក្លាហាន ការថ្លៃថ្នូរថែមទៀតផង ។

១៣- អំពីរថយន្ត:- រថយន្តទាំងឡាយ ទោះបីតូចក្តីធំក្តី ដែលបើកបរក្នុងទី-ក្រុងក្តី-ខេត្ត-ស្រុក-ឃុំ-ភូមិ គេប្រើនប្រយ័ត្នប្រយ៉ែងណាស់ ទីណាដែលកុះករដោយមនុស្សម្នាមហាជន គេបើកតិច បង្អន់សន្ទុះមិនឲ្យលឿនហួសប្រមាណទេ ពីព្រោះគេការពារដល់ការអន្តរាយផ្សេងៗ ទាំងមិនដាក់ផ្ទុកអីវ៉ាន់លើដំបូលរថយន្តឲ្យហួសបំណុះទេ តាមការពិត គេមិនឲ្យផ្ទុកអីវ៉ាន់លើដំបូលរថយន្តផង ។ អ្នកដែលធ្វើដំ-ណើរតាមរថយន្ត មានការទៅមកដោយស្រួល ទាំងអ្នកម្ចាស់រថយន្តទាំងឡាយប្រើអាការៈល្អ សំដីទន់ភ្លន់ទៅរកអ្នកដំណើរ មិនប្រើសំដីគំហ៊កគំហល់គំហែងសោះឡើយ ។ ទាំងកុប៉ាល់ឬកាណូតក៏ដូចគ្នា គេមានការថែទាំស្អាតបាតជានិច្ច ហាមមិនឲ្យយកក្រណាត់សំពត់ដាច់ដាច ឬបំណែកបារីកណ្តាប់កណ្តោចយកទៅបិទបាំងក៏ដៅវៃឡើយ ព្រោះគេយល់ថាកិច្ចការទាំងនេះតូចតាចពិតមែន តែបើពួកការបណ្តែតបណ្តោយការនេះជាហេតុនាំឲ្យខូចដំរៀ ខូចកិត្តិយសរបស់ប្រទេសពិត ព្រោះហេតុនោះ អ្នកពួកការទាំងឡាយហាមប្រាមអ្នកម្ចាស់កុប៉ាល់-កាណូត មិនឲ្យធ្វើការខ្ជាខ្ជាយកវត្ថុមានសំពត់ដាច់ដោចទៅបិទបាំងទេ ។ បើគ្មានការបង្គាប់បញ្ជាយ៉ាងនេះ កាលបើអ្នកទេសចរពីប្រទេសក្រៅ ធ្វើដំណើរត្រាច់ទៅមកពីប្រទេសមួយទៅប្រទេស-មួយ គេអាចតិះដៀលបាន ព្រោះខ្វះសីលធម៌ខាងការស្អាតបាត ។ នៅគេស្ថាន

តាមវិថីតូច-ធំទៀតសោត  គេមិនឲ្យហាលវត្ថុមានសំពត់អាវជាដើមរណែងរណោងទេ គឺត្រូវមានកន្លែងសម្រាប់ហាលដោយឡែក  មានរបៀបបែបផែនគួរល្អមើលគួរជាទីទស្សនាការ ។

នៅប្រទេសខ្មែរយើង  សម័យមុនពួកចៅកែ កុប៉ាល់ កាណូត ទីងនាវាតូចធំទាំងឡាយ  មានការថែទាំនាវារបស់ខ្លួនដោយត្រឹមត្រូវល្អ  ទាំងមិនបណ្ដែតបណ្ដោយឲ្យពួកកម្មករ ធ្វើការតាមមានតាមបានឡើយ ។  លុះដល់ជំនាន់ស្រុកក្រ  ក្រណាត់ឡើងថ្លៃគ្រប់នាវាទាំងឡាយ  ដែលបើកបរតាមទន្លេ ស្ទឹង យកក្រណាត់សំពត់ដាច់ដាចនឹងក្រណាត់បាវដាច់រដោចទៅបិទបាំងកំដៅថ្ងៃជានិច្ចនិរន្តរ៍  តែដល់ស្រុកសម្បូរសប្បាយ អំពើដែលធ្វើដោយខ្ជីខ្ជានោះៗ នៅជឹតជាប់រហូតដល់សព្វថ្ងៃ គេពុំបានផ្លាស់ប្ដូរទៅតាមកាលៈទេសៈសោះឡើយ ។  ទាំងទង់ជ័យ  ដែលត្រូវដោតបង្ហើរលើនាវាទាំងឡាយទៀតសោត ខ្លះដោតឲ្យតែមានបាន ខ្លះគួរវាសឲ្យខាងតែបាន អ្នកផងមើលទៅ ពុំឃើញប្រាកដថា  ទង់ជ័យដែលគេដោតលើនាវាទាំងនោះ  ជាទង់ជ័យប្រចាំប្រទេសណា  មានសណ្ឋានទ្រង់ទ្រាយដូចម្ដេច  មានវិចិត្រដោយរូបភាពអ្វីខ្លះទេ ព្រោះហេតុនោះ  នៅគ្រប់ប្រទេសទាំងឡាយ  ដែលស្ថិតនៅជិតខាងប្រទេសយើង គេប្រយ័ត្នណាស់  មិនឲ្យធ្វើខ្ជីខ្ជាទេ ទាំងអក្សរដែលសរសេរដាក់ឈ្មោះម្ចាស់ផ្ទះ  នៅគ្រប់ផ្លូវគ្រប់ច្រកល្ហកទៀតសោត  ក៏គេចាត់ការឲ្យសរសេរដាក់ឲ្យត្រឹមត្រូវផងដែរ  គេឲ្យមានផ្ទាំងក្ដារ  ឬផ្ទាំងបន្ទះស័ង្កសីតូចធំប៉ុនគ្នា  ស្នាមគំនូសអក្សរប៉ុនៗគ្នា ខ្ពស់ទាបដូចគ្នាទាំងអស់,  នៅផ្លូវណាប្រើអក្សរធំ ក៏ធំទាំងអស់, ផ្លូវណាប្រើអក្សរកណ្ដាលៗទាំងអស់ ផ្លូវណាតូចល្មមៗទាំងអស់, អ្នកផងមើលទៅអំពីចម្ងាយរត់របត់ផ្លូវ មិនទើសភ្នែកឡើយ ។

១៨៖ អំពីគ្រឿងបរិភោគ អាហារនៅសហភាពភូមាស្រដៀងគ្នានឹងអាហារនៅប្រទេសខ្មែរដែរ (តែអង្ករច្រើនទន់ ចំអិនអាហារទទួលទានស្រួល) ដែលប្លែកគ្នានោះគឺ សម្ល នឹងបង្អែមខ្លះៗ តាមធម្មតា នៅប្រទេសខ្មែរយើង និយមប្រើខ្លាញ់សម្រាប់បង់លាយជាមួយសាច់ឬបន្លែផ្សេងៗ ទាំងបង្អែមខ្លះៗ ក៏និយមប្រើខ្លាញ់ដែរៗតែនៅសហភាពភូមា ប្រជាជនទូទៅនិយមប្រើប្រេងដូង ឬប្រេងសណ្ដែក សម្រាប់បង់លាយជាមួយសម្ល ឬបង្អែមគ្រប់យ៉ាង ៗ ឯទឹកគ្រឿងខុសពីប្រទេសយើង ទឹកគ្រឿងសម្រាប់ជ្រលក់ផ្អាប់ជាមួយបន្លែគ្មានទឹកទេ គ្រាន់តែផ្អាប់ជាមួយបន្លែជាការស្រេច ៗ ឯគ្រឿងផ្អាប់នោះៗ ធ្វើពីកម្ពិសតូចៗ គេហៅថា ត្រូវគ្នានឹងភាសាយើងថា “កាពិ” គេបុកម្ទេះដាក់លាយជាមួយគ្នាផង ៗ

បង្អែម១បែបដែលយើងពុំធ្លាប់ដែលធ្វើ, របៀបធ្វើប្រហែលគ្នានឹងចេកចៀនដែរ តែនៅប្រទេសយើង ច្រើនដាក់ចេកធ្វើជាស្នូល ៗ ឯប្រទេសគេ ចេកចៀនក៏មានដែរ តែមានបង្អែម១បែបទៀត ហៅថាត្រឡាចចៀន គេចិតត្រឡាចជាចំណិតតូច ៗ ដាក់ចំកណ្ដាល របៀបចៀនដូចគ្នាចេកចៀនមានដាក់ប្រេងនឹងម្សៅលាយលើ ៗ ដូចគ្នា វេលាទទួលទានគេផ្អាប់ជាមួយនឹងស្លឹកស្ពៃ សាឡាដ់ ខាត់ណា នឹងជីផ្សេង ៗ ព្រមទាំងទឹកគ្រឿងផង ៗ គួរតែធ្វើទទួលទានសាកលមើលកុំខានបើឃើញថាស្រួល គប្បីធ្វើឲ្យច្រើនតាមគាប់ចិត្ត ៗ

១ បែបទៀត គេហៅថា “ កម្ពិសចៀន ” របៀបចៀនដូចគ្នានឹងត្រឡាចចៀនដែរ ដំបូងគេដាក់ប្រេងទៅក្នុងខ្ទះរួចដាក់ម្សៅពេយបន្តិច ៗ ពីលើ ហើយគេយកកម្ពិសនោះពីលើថែមទៀត តែកុំដាក់ម្សៅច្រើនពេក គេដាក់កម្ពិសច្រើន

ដាំង ពេលទទួលទាន ត្រូវផ្សំគ្រឿងទន្ទឹងបន្លែ ទឹកជ្រលក់ដូចគ្នានឹងត្រឡាចចៀនដែរ ។ របៀបនេះ គួរធ្វើទទួលទានសាកមើលដែរ បើឃើញថាឆ្ងាញ់ពិសា ចូរធ្វើឲ្យញយ ៗ ទៅ ។

១៥– របបពិសេស៖ ប្រជាជនកម្ពុជា ពួកជនអ្នកទីទ័លក្រគេពុំដែលឃើញ ទៅប្រកបការងារជាទាសកម្មករ លីសែងរែកពុនឲ្យជនជាតិដទៃ ដូចជាជាតិចិន ហិណ្ឌូ ឥណ្ឌៀទេ ខុសគ្នាពីប្រជាជនខ្មែរនៅប្រទេសខ្មែរ នៅតាមក្រុង-ខេត្ត-ស្រុកភូមិឃុំតាមផ្សារផ្សា គេតែងជួបប្រទះប្រជាជនជាតិខ្មែរអ្នកទីទ័លក្រ សែង លី ពុន រែក អីវ៉ាន់ឲ្យជនជាតិចិនជាញឹកញាប់ណាស់ ។ ឯប្រជាជនកម្ពុជាប្រកាន់ខ្លួនជាដាច់ខាតចំពោះអំពើនេះ បើជាខ្លួនក្រីក្រ ស៊ូបេកខ្លួនទៅធ្វើជាគូលីរាជការខ្វះរាជការ ស៊ីប្រាក់ខែរាជការ មិនឲ្យជាតិដទៃ ប្រើខ្លួនជំនួសសត្វពាហនៈ ដូចជាក្របីគោ សេះដំរីទេ ទាំងជាហេតុនាំឲ្យថោកសញ្ជាតិផង ។

១ទៀត អស់រយៈកាលដ៏យូរមកហើយ គេពុំដែលឃើញរដ្ឋាភិបាលកម្ពុជា ចាត់ប៉ូលិសឲ្យស្ទាយកាំភ្លើងបណ្ដើរពួកចោរដើរកាត់ផ្សារផ្សាទៅធ្វើការងារផ្សេង ៗ ទេគេឃាំងទុកក្នុងពន្ធនាគារ ឲ្យធ្វើការងារផ្សេង ៗ តាមមុខការដែលត្រូវធ្វើក្នុងពន្ធនាគារៗ ការធ្វើយ៉ាងនេះ ដើម្បីបំបាត់ចោលនូវអំពើឃោរឃៅ ការស្អប់ស្អែងនៃអ្នកជនដទៃ ។ល។...

(១៥)៖ យោបល់ពិសេស៖ អំពីរស្មីនៃឯកពជ្រ នៅប្រទេសកម្ពុជាយើង មានព្រះមហាក្សត្រជាប្រមុខ ជាទីគោរពនៃពលរដ្ឋខ្មែរទូទៅទាំងប្រទេស, តាំងពីបុរាណសម័យរៀងរាបដរាបដល់បច្ចុប្បន្នសម័យ ប្រជាជនខ្មែរទាំងសកលតែងមានការគោរពនឹងស្វាមី

ភក្តីដ៏ជ្រាលជ្រៅចំពោះព្រះមហាក្សត្រ ប្រចាំប្រទេសរបស់ខ្លួនយ៉ាងស្មោះស្ម័គ្រ ទុកដូចជាសរណវត្ថុ ដែលជាទីស្រឡាញ់ ជាទីគោរពបូជាដែរ ។ ប្រទេសដែលមានព្រះមហាក្សត្រទ្រង់រាជ្យ ទុកដូចជាមហាប្រាសាទប្រដាប់ដោយកំពូល ឬដូចជាគ្រឹស្ថានទីង វិមានដែលមានសសរស្តម្ភដែរ ។

បុរាណសម័យ ប្រទេសខ្មែរយើង មានពន្លឺរស្មីរុងរឿងក្រៃពេក ហាក់ដូចជាព្រះចន្ទពេញវង់ នាតិត្តិទី១៥កើតមានកិត្តិស័ព្ទល្បីល្បាញពាសពេញសកលលោក ប្រទេសជិតខាងគោតសរសើរស្ងើចថ្លៃដែងចំណាននៃបុព្វបុរសខ្មែរយ៉ាងមហស្ចារ្យ ។ ពលរដ្ឋខ្មែរទាំងអស់សប្បាយរីករាយយ៉ាងក្រៃលែង ឥតមានព្រួយបារម្ភអ្វីឡើយ ព្រោះគ្មានសត្រូវនោះខាងក្នុងប្រទេស ខាងក្រៅប្រទេសក្តី ក៏ប្រកបដោយសន្តិសុខសន្តិភាពដូចគ្នា រដ្ឋាភិបាលមានសិទ្ធិនឹងសេរីភាពពាត់ការគោងប្រទេសបានដោយសេរី ៗ លុះកន្លងមករវាង៨០ឆ្នាំប៉ាយប៉ុណ្ណោះ ប្រទេសខ្មែរយើងដុនដាបធ្លាក់ទៅនៅក្នុងកណ្តាប់ដៃនៃពួកជនបរទេស កិច្ចការគ្រប់យ៉ាងនៅលើកណ្តាប់ដៃនៃជនបរទេសទាំងស្រុង អសន្តិសុខកើតពាសពេញនៃផ្ទៃប្រទេស ប្រជាជនខ្មែររវាតសាមគ្គីភាពរវាងជនមានសញ្ជាតិដូចគ្នាអស់ ថែមទាំងកើតទុក្ខទោរម្នេញពល់ទិវារាត្រី គ្មានបុគ្គលរូបណា មានគំនិតខិងរែងអង់អាចមានសមត្ថភាព នឹងប្រតិពលព្រមទាំងប្រាជ្ញាបារមីអាចត្រិះរិះពិចារណាឃើញធ្លុះធ្លាយ ឬមាន។បាយដ៏ក្លាហានកាប់គ្រាយក្តារនូវអំពើឃោរឃៅ អំពើយង់ឃ្នង ការរំលំជាន់ ការសង្កត់សង្កិនដោយពលការអំពើសំណាក់ពួកជនបរទេសបានឡើយ ទោះបីអ្នកនោះមានសមត្ថភាពបែបណាក៏ដោយ ពីព្រោះពួកជនជាពលរដ្ឋខ្មែរគ្រប់រូបមានសម្បទាពុំគ្រប់គ្រាន់ប្រើនតែគិតត្រឹមតែប្រយោជន៍ផ្ទាល់ ៗ ខ្លួនមួយ ឬក្រុមគ្រួសារ

១ក្រុម ៗ ប៉ុណ្ណោះ មើលពុំឃើញឆ្ងាយ ស្តាប់ជិត ៗ ផ្តល់ប្រយោជន៍ពុំបានទៅទាំងប្រទេស ។

សម័យបច្ចុប្បន្ននេះ ប្រទេសកម្ពុជា មានមហាក្សត្រជាប្រធាន ជាទីតាំង ហាក់ដូចជាប្រាសាទពេជយន្តដែលមានកំពូលជាទីតាំង មានផ្កាហ្វូត្តាញ់គ្រឿងអលង្ការ មានក្បូរក្បាច់រចនាជាគ្រឿងលំអរ មានសម្តេចព្រះឧបយុវរាជជានាយចង្កូត ទឹងជាមគ្គុទ្ទេសក៏ព្រោះព្រះអង្គមានព្រះបញ្ញាដ៏មោះមុត មានសមត្ថភាពដ៏ក្លាហាន មានមធុរវាចាដ៏ពិរោះពិសាគួរជាទីចាប់ចិត្តនៃពលរដ្ឋខ្មែរទូទៅទាំងប្រទេស សូម្បីព្រះអង្គធ្វើដំណើរទៅកាន់ប្រទេសណាទោះជិតក្តីឆ្ងាយក្តី ពួកជនក្នុងប្រទេសនោះ តែងកោតស្ញើចសរសើរបុកពារនឹងសេចក្តីថ្លៃថ្នូរ ប្រាជ្ញាបារមីព្រះអង្គស្ទើរតែគ្រប់រូប ព្រោះហេតុនោះ ក្នុងពេលទុតិយសន្និបាតនៃឆដ្ឋសង្គាយនា ព្រះអង្គទ្រង់ធ្វើព្រះរាជដំណើរទៅទស្សនាការ ស្ថាន-ការនៅក្រុងរ៉ង់គូនសហភាពភូមា ពេលនោះពលរដ្ឋសហភាពភូមា ទាំងមន្ត្រីទាំងរាស្ត្រ ទាំងចាស់ទាំងក្មេង តែងមានសោមនស្សចេតនា នឹងស្វាមីភក្តិចំពោះព្រះអង្គរហូតដល់សព្វថ្ងៃនេះ ។ ម្យ៉ាងទៀតពលរដ្ឋខ្មែរគួរតាំងទុកថា ព្រះអង្គជាបរមក្សត្រមួយព្រះអង្គ មានសញ្ជាតិជាក្សត្រជាប់ទាក់ទងមកតាំងពីសម័យអង្គរវត្ត ក្នុងវង្សវរខ្មែរដោយពិត ព្រោះទ្រង់មានព្រាជ្ញយោបល់វែងឆ្ងាយ យល់ប្រយោជន៍ដល់ជាតិសាសនាដ៏ជាក់ស្តែង ៗ បើទុកជាទ្រង់ពុំទទួលគ្រឿងរាជសម្បត្តិក៏ ពុំទ្រង់ទទួលចាត់វិធានការណ៍ផ្សេងៗដើម្បីប្រទេសជាតិក្តី ក៏ព្រះអង្គឥតលំបាក ឥតនឿយព្រួយព្រះអង្គឡើយ ទាំងឥតមានបុគ្គលរូបណាស្អប់ខ្ពើម ឬរិះគន់មើលបំណាំប្រឆាំងវាសនាបារមីព្រះអង្គបានឡើយ គង់តែក្លាយទៅជាឧត្តមបុរស១រូបដ៏វិសេសវិសាលជាងបុរសទាំងឡាយ ដែលមានសញ្ជាតិជាខ្មែរដែរ ។

ចុះហេតុដូចម្ដេច បានជាទ្រង់ធ្វើឲ្យលំបាកព្រះអង្គ ទាំងជាហេតុនាំឲ្យប្រជាជនខ្មែរខ្លះៗ ពុំបានគិតវែងឆ្ងាយ ពុំយល់ប្រយោជន៍សាធារណៈ តិះដៀលបង្អាប់បន្តុះ ពោលលើកទោស ការពិតទៅជាមិនពិត ការមែនទៅជាមិនមែនទៅវិញ?

ឆ្លើយថា– ព្រោះព្រះអង្គមានព្រះរាជយោបល់ដ៏ភ្លឺថ្លា មានព្រះបញ្ញាដ៏មោះមុត មានសមត្ថភាពដ៏ក្លាហាន មានព្រះរាជតម្រិះត្រូវ យល់ប្រយោជន៍សាធារណៈទ្រង់ពុំស្ដាយស្រណោះដល់អាយុសង្ខារ ព្រោះទ្រង់មានស្នាមភ័ក្ត្របំពោះប្រទេសជាតិ បំពោះពលរដ្ឋខ្មែរ ទ្រង់ខំតស៊ូទាមទារឯករាជ្យសិទ្ធិសេរីភាពគ្រប់យ៉ាង ជូនបំពោះពលរដ្ឋខ្មែរ ព្រមទាំងប្រកាសឃោសនា ដាស់តឿនក្រើនរំឭកដល់ពលរដ្ឋទាំងអស់ក្នុងព្រះរាជអាណាចក្រ ឲ្យជួយជ្រំជ្រែងកសាងជាតិ សាសនាជាមួយព្រះអង្គ ឲ្យធ្វើការដើម្បីជាតិមាតុប្រទេស ស៊ូស្លាប់ជាមួយនឹងជាតិដូច្នេះជាដើម ព្រះស្ទូរសីហនាទនេះហើយដែលល្បីល្បាញខ្ទរខ្ទារគ្រប់ទិសានុទិសក្នុងពិភពលោក ។ បើទុកជាមានឧបសគ្គយ៉ាងក៏ដោយ ក៏ទ្រង់ពុំរួញរា ពុំភោតញញើត មិនសុខចិត្តថយក្រោយ មានតែលឿនទៅមុខតែម្យ៉ាង ដូច្នេះពលរដ្ឋខ្មែរទាំងឡាយ ទាំងគ្រហស្ថទាំងបព្វជិត ទាំងចាស់ក្មេងគ្រប់ជំណាន់ គ្រប់ឋានៈគ្រប់ថ្នាក់គ្រប់ជាន់ថ្នូរកុំព្រងើយកន្ដើយ កុំមើលបំណាំ កុំចាំតែថ្កោលទោស កុំរំលប់គុណ គប្បីនាំគ្នាចងសាមគ្គី រក្សាឯករាជ្យ ពួតដៃគ្នាកសាងប្រទេសជាតិ ដើរតាមគម្រោងដែលព្រះអង្គទ្រង់ត្រាយទុកមកហើយ ទុកព្រះអង្គជានាយកដ៏ឆ្នើម នឹងជានាយកបញ្ជាការដ៏វិសេស សម្រាប់ប្រទេសអស់កល្បាវសានតទៅកុំបីឃ្លាតក្លាយទៅជាប្រការដទៃឡើយ ។

សមណនិស្សិតខ្មែរ នៅធម្មទូតមហាវិទ្យាល័យក្រុងរង្គូន សហភាពភូមា ។

ភិក្ខុ សីលគុត្ដោ (ថោង-ទិត



## សាសនាជេន និងពុទ្ធសាសនា

បណ្ដាសាសនាធំៗ ដែលកើតមាននៅក្នុងប្រទេសឥណ្ឌា សាសនាជេន ក៏ជាសាសនា មួយមានអាយុវែង ហើយមានជនកាន់អានច្រើន ដ៏រាបដល់សព្វថ្ងៃនេះ ។ ប៉ុន្តែសាសនានេះ ពុំអាចផ្សាយឥទ្ធិពលទៅកាន់ប្រទេសនានា ក្រៅពីប្រទេសឥណ្ឌាបានទេ ព្រោះប្រទេសស៊ីវិល័យទាំងឡាយក្នុងលោក ពុំអាចប្រតិបត្តិតាមសាសនានេះបាន ដោយសាសនានេះ ប្រកាន់ធម៌អត្តកិលមថានុយោគខ្លាំងពេក ។ អ្នកបួសប្រពឹត្តអាក្រាត, ប្រពឹត្តដកសក់ដោយសណ្ដាស ឬដោយវត្ថុផ្សេងៗ មានគ្រាប់ត្នោតជាដើមដែលអាចដកបាន, បរិភោគអាហារក្បៀនក្នុងដៃ ពុំមានបាត្រ ឬភាជន៍អ្វីឡើយ, រដូវរងាប្រព្រឹត្តធ្វើតបៈក្នុងទីមួប់ត្រជាក់, លុះរដូវក្ដៅប្រព្រឹត្តធ្វើតបៈ កណ្ដាលវាលហាល

ថៃ, ប្រពឹត្តមិនថ្ងៃតទីគប៉ុណ្ណោះជាដើមជាហេតុធ្វើឲ្យមានកម្លាំងខ្លាំងក្នុងការផ្សាយឥទ្ធិពលទៅកាន់ការប្រទេសនានាក្នុងលោក ។

អ្នកប្រាជ្ញខាងសាសនាជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះម៉ូរីសវិនទែនិត្ស (Maurice vinternitz) ជាអ្នកសរសេរសៀវភៅឈ្មោះ ប្រវត្តិវណ្ណគតិឥណ្ឌា History of Indian Literoture) បានបញ្ចេញមតិថា សាសនាជេនជាសាសនាចាំសម្បក គឺផ្សាយបានតែក្នុងប្រទេសឥណ្ឌា, ឯពុទ្ធសាសនាជាសាសនាសាកល អាចផ្សាយទៅកាន់ទីណាក៏បាន ។

ប៉ុន្តែប្រជាជនប្រមាណ ១០ ភាគរយក្នុងប្រទេសឥណ្ឌា នៅប្រកាន់ជឿកាន់សាសនានេះយ៉ាងជិតស្និទ្ធ ដោយយល់ថាសាសនានេះប្រកាន់ធម៌សន្តោស ទីឯខ្ទង់យ៉ាងខ្ពង់ខ្ពស់ ហើយមានប្រាសាទសស្រទៃថ្លាដ៏ជ្រាលជ្រៅផង ។

តាមដំណឹងសាសនា ថាសាសនាជេនបានកើតឡើងមុនព្រះពុទ្ធសាសនាបន្តិចដោយសាស្តាឈ្មោះមហាវីរៈ ឬ និគណ្ឋនាដបុត្ត (តាមដែលមានមកក្នុងគម្ពីរពុទ្ធសាសនា) ។ អ្នកប្រាជ្ញខាងសាសនាជេនបានកត់ប្រវត្តិទុកថា មហាវីរៈ បានប្រសូត្រចេញពីផ្ទៃមាតា មុនគ្រិស្តសករាជ ៥៩៩ ឆ្នាំ, ចេញបួសអាយុ ៣០ ឆ្នាំ, ធ្វើទុក្ករកិរិយាអស់ ១២ ឆ្នាំ បានសម្រេចកេវលញ្ញាណ (គឺញាណដែលខ្ពស់បំផុតរបស់មហាវីរៈ) ក្នុងអាយុ ៤២ ឆ្នាំ, និព្វានក្នុងអាយុកាល ៧២ ឆ្នាំ គឺក្នុងឆ្នាំ ៥២៧ មុនគ្រិស្តសករាជ ។ (ពួកជេនិកសាវ័កជឿជាក់ថា មហាវីរៈបានសម្រេចនិព្វានដូចជាព្រះពុទ្ធដែរ) ។

## មហាវីរៈកើតមុនព្រះពុទ្ធជាម្ចាស់ឬ?

អំពីការកើតមុនក្រោយនៃពុទ្ធសាសនាទីងសាសនាជេន ទីងសូមពណ៌នាជាខាង

ក្រោយ ៗ ទីនេះសូមពណ៌នាអំពីមហាវីរៈ និងព្រះពុទ្ធ, ណាកើតមុន ណាកើតក្រោយ, ដែលតែងមានការកាន់ប្រឡំទឹងផ្ទុយមតិគ្នាជាច្រើន ៗ

ពុទ្ធសាសនាកប់ពីត្រឹមព្រះពុទ្ធបរិនិព្វានថយក្រោយបាន ៥៤៣ ឬ ៥៤៤ ឆ្នាំមុនគ្រិស្តសកពជ, បើកប់តាំងពីព្រះអង្គប្រសូត្រ ៨០ ឆ្នាំបញ្ចូលផង បាន ៦២៣ ឬ ៦២៤ ឆ្នាំមុន គ.ស. ៗ ដូច្នេះបើធៀបនឹងឆ្នាំកំណើតរបស់មហាវីរៈ ដូចពណ៌នាខាងដើម (៥៩៩ ឆ្នាំមុន គ.ស.) ឃើញថាព្រះពុទ្ធជាម្ចាស់កើតមុនមហាវីរៈ (និគណ្ឋនាដបុត្ត) ៗ ប៉ុន្តែ គម្ពីរពុទ្ធសាសនាយើង ដូចក្នុងសាមញ្ញផលសូត្រ (ទីឃនិកាយ) ជាដើម ច្រើនពណ៌នាដែលអាចឲ្យយកសេចក្តីបានថា មហាវីរៈ មានអាយុច្រើនជាងព្រះពុទ្ធជាម្ចាស់ ៗ តោះបីយ៉ាងនោះក៏មិនខុសគ្នាឆ្ងាយណាស់ណាទេ ព្រោះអាចឲ្យសន្មតបានជាព្រះពុទ្ធជាម្ចាស់ និង មហាវីរៈ បានត្រាស់ដឹងផ្សព្វសាសនាក្នុងជម្ពូទ្វីប ក្នុងយុគសម័យជាមួយគ្នា ដោយមានអាគតដ្ឋានជាច្រើនក្នុងសុត្តន្តបិដក ៗ

ប៉ុន្តែ មានអ្នកនិពន្ធខ្លះ ដោយការក្ញាត់គំនិតឬដោយពុំបានពិចារណាឲ្យសមហេតុសមផល ចូលចិត្តសរសេរថា «មហាវីរៈ ជាសាស្តារបស់ពួកនិគ្រន្ថតីរ្ថិយ៍ កើតមុនព្រះពុទ្ធជាម្ចាស់យើងជាច្រើនឆ្នាំ» ៗ ពាក្យថា «ច្រើនឆ្នាំ» ក្នុងទីនេះបើយ៉ាងតិចក៏ពីរ ឬ បីឆ្នាំ ៗ ក្នុងរឿងនេះសូមត្រិះរិះតាមវិចារណន័យដូចតទៅ ៖ មនុស្សសម័យនោះមានអាយុកប្បប៉ុន្មានឆ្នាំ?, បើមហាវីរៈ កើតមុនព្រះពុទ្ធជាច្រើនឆ្នាំ តើអាចមានអាយុវែងដល់ពុទ្ធកាល ឬ?, ឬក៏អស់អាយុមុនពុទ្ធកាល? ក្នុងសុត្តន្តបិដក មានអាគតស្ថានជាច្រើនកន្លែងដែលពណ៌នា អំពីការប្រជុំសន្ទនាគ្នាទៅវិញទៅមករវាងនិគណ្ឋនាដបុត្ត គឺមហាវីរៈ និងព្រះពុទ្ធជាម្ចាស់ ដូចក្នុងឧបាលិសូត្រ,

អកយសុត្រ (មជ្ឈិមនិកាយ) ជាដើម ពុំមែនឬ? បើដូច្នេះគេនឹងវិនិច្ឆ័យបែបណា ឲ្យសមហេតុសមផល? ។

សាសនាជេន ប្រាកដជាកើតមុនពុទ្ធសាសនាច្រើនរយ ឬ ច្រើនពាន់ឆ្នាំមែន?

ជេនិកបណ្ឌិតឈ្មោះអមរចន្ទ (Amar chand) បានសរសេរថា មហាវីរៈ ពុំមែនជាសាស្ដាដើមដំបូងបំផុតរបស់សាសនាជេនទេ គឺជាសាស្ដាទី ២៤ ចុងក្រោយគេបំផុត, គេហៅថា តិត្ថំករ (អ្នកសាងនាវាឆ្លងវដ្ដ ឬ ទំពង់) ទី ២៤ ។ ឯតិត្ថំករ ២២ រូបខាងដើម អ្នកនិពន្ធនោះពុំបានពោលដល់, គេនិយាយតែអំពីតិត្ថំករទី ២៣ ឈ្មោះបាស៊្វនាថ ។ សាស្ដាបាស៊្វនាថ បានប្រកាសប្រឆាំងយ៉ាងខ្លាំង ចំពោះការប្រព្រឹត្តលាមកជាគម្រង់ក្នុងសង្គម ព្យាយាមលើកសង្គមធ្វើសង្គមឲ្យបរិសុទ្ធ ប្រមាណ ២៥០ ឆ្នាំមុនមហាវីរៈ ។ ប៉ុន្តែកាលសាស្ដា បាស៊្វនាថអស់អាយុទៅ សង្គមក៏បានធ្លាក់ចុះក្នុងគម្រង់លាមកវិញដូចដើម, តែនៅមានអ្នកបួសតាមសាស្ដានោះខ្លះ ៗ ដរាបដល់មហាវីរៈកើតឡើង ។ ប្រវត្តិបានពណ៌នាថា ស្ដេចវង្សត្រកូលរបស់ មហាវីរៈ ក៏ធ្លាប់ជាសាវ័ក ឬ ជាបរិស័ទនៃ សាស្ដា បាស៊្វនាថត ៗ គ្នាតាំងពីដើមរៀង ៗ មក ។

គទៅសូមអានជីវប្រវត្តិសង្ខេបរបស់មហាវីរៈ ដែលបានដកស្រង់ពីអាគតស្ថានផ្សេង ៗ ដែលអ្នកប្រាជ្ញខាងសាសនាជេន បានសរសេរទុកមក៖

ជាតិភូមិ និងវង្សត្រកូលរបស់មហាវីរៈ

មហាវីរៈកើតក្នុងកុណ្ឌបុរី ជិតក្រុងវេសាលី, ប្រមាណ ២៨ម៉ៃល៍ (ប្រហែល ៤០ គ.ម.) ខាងជើងក្រុងបត្នៈ, ក្នុងសម័យបច្ចុប្បន្ន, ក្នុង ញាតិកវត្តិយត្រកូល, ដូលកាលហៅថានាយត្រកូល (បានជាពេលក្រោយមកគេហៅមហាវីរៈ ថា នាថបុត្ត)

ក្នុងកស្សបគោត្រ ។ បិតាឈ្មោះសិទ្ធាថិ (ពុំមែនសិទ្ធាថ គឺព្រះពុទ្ធទេ) ជួនកាលគេហៅថា ស្រេយាំសៈ ឬ យសាំស ។ មាតាឈ្មោះព្រះនាងត្រិសាលា ជួនកាលគេហៅថា វិទេហទត្តា ឬ ប្រិយការិនី, កើតក្នុងវសិដ្ឋគោត្រ ។ ព្រះនាងជាព្រះរាជភគិនីនៃព្រះបាទចេដក សោយរាជ្យនៅនគរវិទេហៈ ។

ក្នុងឆ្នាំ ៥៩៩ មុនគ.ស. ថ្ងៃ ១៣ កើតខែចេត្រ មហាវីរៈ បានប្រសូត្រចេញពីផ្ទៃមាតា គឺនាងត្រិសាលា, ប្រកបដោយសេចក្ដីសុខក្សេមក្សាន្ត ទាំងមាតា ទាំងបុត្រ ។ គម្ពីរជេនឈ្មោះកល្បសូត្រ បានពណ៌នាយ៉ាងវែងអំពីការសប្បាយរីករាយសុខក្សេមក្នុងវង្សត្រកូល, ពន្លឺរស្មីព្រោងព្រាតក្នុងនិវេសនដ្ឋាននិងតាមវិថី, ការដោះលែងអ្នកទោស និងការបរិច្ចាគទានយ៉ាងអធិកអធម ក្នុងថ្ងៃកំណើត នៃទារកមហាវីរៈ ។

## នាមនិងនាមបញ្ញត្តិរបស់មហាវីរៈ

ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់យើង មាននាមនិងនាមបញ្ញត្តិច្រើន ដូចកាលពីកុមារ គេហៅថា សិទ្ធត្ថ គោតមជាដើម, លុះបានសម្រេចសម្មាសម្ពោធិញាណហើយ បាននាមបញ្ញត្តិថា អរហំ សម្មាសម្ពុទ្ធោជាដើម យ៉ាងណា, មហាវីរៈ ក៏យ៉ាងនោះដែរ កាលនៅជាកុមារគេហៅថា វេសាលិយៈ (ជាជាតិវេសាលី), វិទេហៈ (ជាបុត្តរបស់នាងវិទេហទត្តា), កាលបានសម្រេចញាណ ៥ ប្រការហើយ គេហៅថា អរហន្ត (អ្នកគួរដល់ការគោរព), អរិហន្តៈ (អ្នកកំចាត់សត្រូវ), អរុហន្តៈ (អ្នករំលើងនូវឫសគល់នៃកម្ម), សាសននាយកៈ (ជានាយក ឬ ប្រធាននៃសាសនា) ពុទ្ធៈ (អ្នកភ្ញាក់រលឹក ឬអ្នកសម្រេចនូវញាណជាន់ខ្ពស់) ។ (ញាណ ៥ ប្រការនឹងមានពណ៌នាខាងក្រោយ) ។

(នៅមានត)

# ពិធីបុណ្យឆ្លងឆដ្ឋសង្គាយនា (ត)

មុនពេលបើកសម័យប្រជុំបន្តិច លោកនាយកពិបុលសង្គ្រាមព្រមទាំងលោកស្រីនឹងក្រុមបេសកជនសុសព្ចតនារបស់ថៃ បានលើកជូននូវព្រះពុទ្ធបដិមាករជាវិការនៃទង់ដែងមួយព្រះអង្គទៅលោកនាយករដ្ឋមន្ត្រីប្រទេសភូមា ដើម្បីជាទីរឭកនៃស្យាមសន្និ-បាតនឹងទុកជាទីគោរពនមស្ការនៃពុទ្ធមាមកជនជាតិភូមាផង ។

សម័យប្រជុំលើកនោះបានបើកឡើងដោយលោកនាយករដ្ឋមន្ត្រីប្រទេសថៃ ហើយបានសម្តេចព្រះវន្ទរ័ត្នកិត្តិសោភណ សង្ឃនាយកប្រទេសថៃជាប្រធាននៃព្រះសង្ឃជាសង្គីតិការកៈ ។

## ស្រីលង្កាសន្និបាត

៥– បញ្ចមសន្និបាតឈ្មោះថាស្រីលង្កាសន្និបាត គឺសន្និបាតរបស់ប្រទេសស្រីលង្កា ឬ លង្កាទ្វីប, បានផ្តើមពីថ្ងៃ១៣កើតខែចេត្រព.ស.២៤៩៩ (២៣មេសាគ.ស.១៩៥៦) រហូតដល់ថ្ងៃ១៥កើតខែពិសាខ ព.ស.២៥០០ (១) (២៤ឧសភាគ.ស.១៩៥៦) ទើបបប់ អស់រយៈកាល៣១ថ្ងៃគត់ ។

សម័យប្រជុំបានបើកឡើងដោយលោកជយវីរកុរុ រដ្ឋមន្ត្រីក្រសួងធម្មការនឹងសិល្បករប្រទេសស្រីលង្កា, ក្នុងពេលនោះ សម្តេចព្រះមហានាយក វេលិ-វិត ធមិកិតិ អសរណសរណស្រីសរណង្ករគណៈស្យាមនិកាយនៃប្រទេសស្រីលង្កាជាប្រធានសង្ឃ ។

ឯការបំណាយទៅលើសន្និបាតទាំង៥លើកនោះអស់បរិការជាតិយ៉ាងច្រើន ដែលប្រទេសពុទ្ធសាសនិកដូចគ្នាពីបាកនឹងធ្វើតាមបាន ដោយហោចសូម្បីតែការបំណាយ

(១) គ.ស. នៅប្រទេសភូមា២៥០០ក្នុងឆ្នាំនេះ តាមសេចក្តីយល់ផ្សេងពីយើង

ទៅលើចង្ហាន់ព្រះសង្ឃជាសង្គីតិការកៈ ក្នុងមួយថ្ងៃកើនកត្តត្រូវចាយ ៣.០០០ក្យាត់ចាត់ចែងចង្ហាន់ព្រះសង្ឃសង្គីតិការកៈ៥០០អង្គ ចុះបើរាប់តាំងពីថ្ងៃទី១នៃបឋមសន្និបាតរហូតដល់ថ្ងៃទីបំផុតនៃបច្ឆិមសន្និបាតតើអស់ប៉ុន្មានទៅ ? បើសន្និបាតតាំង៥លើកមានចំនួន២៤៨ថ្ងៃ ៗ ឃើញថាមុខចំណាយទៅចង្ហាន់អស់៧៤៤.០០០ក្យាត់ ។

ម្យ៉ាងទៀត នៅពេលបញ្ចប់ឆដ្ឋសង្គាយនាជាពេលពាក់កណ្ដាលនៃព្រះពុទ្ធសាសនា រដ្ឋាភិបាលនិងប្រជាជនជាតិភូមាបានប្រឹងចាត់ចែងពិធីបុណ្យមួយយ៉ាងធំឈ្មោះជាបុណ្យពុទ្ធជយន្តី ឬ បុណ្យ២៥០០ព្រះវស្សានៃព្រះពុទ្ធសាសនារួមជាមួយនឹងបុណ្យឆ្លងឆដ្ឋសង្គាយនានោះឯង ។

ពិធីបុណ្យកំណត់ចូលពីថ្ងៃ១៣កើតខែពិសាខព.ស.២៤៩៩ (២២ឧសភា១៩៥៦) ដល់ថ្ងៃ៣រោចខែពិសាខព.ស.២៥០០ (២៧ឧសភា១៩៥៦) ។

មុនពេលចូលបុណ្យ គណកម្មការចាត់ចែងបុណ្យបានអំពាវនាវសុំឲ្យរដ្ឋាភិបាលដោះបន្ថយទោសពីអ្នកជាប់ទោសក្នុងអាណាចក្រឲ្យបានថយចុះគ្រប់ថ្នាក់នៃទោស ។ រដ្ឋាភិបាលក៏បានអនុមតិយល់ស្របតាមនោះ ហើយដោះបន្ថយទោសនៃអ្នកទោសគ្រប់ពន្ធនាគារដែលជាប់ទោសក្នុងពេលមុនថ្ងៃ ១២ ឧសភាគ.ស. ១៩៥៦ ទៅតាមលំដាប់ថ្នាក់នៃទោសធ្ងន់ស្រាល ។

ការបន្ថយទោសនោះគឺ៖

១– អ្នកមានទោសមួយជីវិតត្រូវបន្ថយមកត្រឹម១០ឆ្នាំ ។

២– អ្នកមានទោសលើសពី១០ឆ្នាំទៅដល់២៥ ត្រូវបានថយមកនៅត្រឹម៧ឆ្នាំ ។

៣– អ្នកមានទោសពី២ឆ្នាំទៅដប់ឆ្នាំត្រូវបន្ថយ ៣-៤ (៣ភាគក្នុង៤) គឺបើជាប់

១០ ឆ្នាំត្រូវបន្ថយមក ២ ឆ្នាំកន្លះ, ៤ ឆ្នាំត្រូវបន្ថយមក ៦ ខែ ។

៤— អ្នកមានទោសពីត្រឹម ៦ ខែចុះមកត្រូវបានរួចខ្លួន ។

រដ្ឋាភិបាលបានប្រកាសឲ្យដោះលែងអ្នកទោសស្រាលៗ ទាំងនោះក្នុងពេលមុនបុណ្យ ៤ ថ្ងៃ ដើម្បីឲ្យអ្នកទាំងនោះមានពេលទៅជួបជុំគ្រួសាររបស់ខ្លួន ហើយនឹងបានរៀបចំដំណើរទៅធ្វើបុណ្យនោះនឹងគេ ។

ឯមុខការងាររដ្ឋាភិបាលបានឈប់ផ្អាកបីថ្ងៃ គឺពីថ្ងៃទី ២៣ ដល់ ២៥ ឧសភា គ.ស. ១៩៥៦ ។

ដទៃពីនោះ រដ្ឋាភិបាលបានហាមប្រាប់ប្រជាជនមិនឲ្យធ្វើអាឃាតសត្វគឺសុំឲ្យប្រជាជនឲ្យអភ័យដល់សត្វទៅក្នុងពេលបុណ្យ មិនតែប៉ុណ្ណោះអាឃាតនដ្ឋានទាំងអស់នៅទីក្រុងវង្គនទីនខេត្តក្រៅត្រូវបិទរវាង ៣ ថ្ងៃ ។

នៅថ្ងៃ ១៣ កើតខែពិសាខ ព.ស. ២៤៩៩ (២២ ឧសភា គ.ស. ១៩៥៦) ពិធីបុណ្យបានបើកឡើង ។ ថ្ងៃនោះជាពេលមាននក្ខត្តឫក្សដ៏អស្ចារ្យដែលក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលមាន គ្រប់គេស្មាននៅក្នុងទីក្រុងនិងខេត្តក្រៅមានដោតទង់ជាតិនិងទង់ធព្វណ្ណរង្សដែលជាសញ្ញានៃទង់សាសនាពីមុខ ហើយនៅពេលយប់មានប្រទីបផ្កាលាក្តុំព្រោងព្រាតវិចិត្រជាក្បាច់ក្បូរផ្សេងៗ ។

នៅលើទួលសិរីមង្គលា បរិយាកាសយ៉ាងត្រជាក់ស្រទន់បានគ្រប់ដណ្តប់ពីលើសន្សើម ៗ បន្តិចម្តងៗ ឯផ្នូនកាលយមហាមេឃក៏បានបញ្ចេញពណ៌ស្អាតខៀវស្រងាត់គួរជាទីត្រជាក់ចិត្តនៃសព្វសត្វ ទាំងពុទ្ធមាមកជនក៏កុកកុកទាំងនាមុនទាំងរាស្ត្រ, ចាស់ក្មេង, ក្រមុំ-កំលោះ, ប្រុស-ស្រីដែលមកពីទីជិតឆ្ងាយនៃរដ្ឋទាំងអស់ក្នុងសហភាពកម្ពុជាៗ

តាមដំណឹងនៃសាពត៌មានឈ្មោះ (Burma Star) ផ្កាយភូមាថាមានប្រមាណជាង ១០០០.០០០ (១០ម៉ឺន) នាក់ ។ ប្រជាជនទាំងនោះ ខ្លះក៏ទៅដោយរថយន្ត ខ្លះក៏ទៅដោយទោចក្រយាន អ្នកខ្លះក៏ដើរ ពពាក់ពពូនគ្នា ពួកខ្លះមានមុខឆ្ពោះទៅមហាបាសាណគុហា ខ្លះសំដៅទៅខាងក្រុមពេនតាំងវត្តផ្សេង ៗ ក្រុមខ្លះទៀតក៏សំដៅទៅរកកន្លែងជប់លៀងដែលសមាគមធំ ៗ នៅក្នុងក្រុងរ៉ង្គូនបានរៀបកេង ៤ កន្លែងយ៉ាងធំ ៗ សម្រាប់ទទួលជប់លៀងភោជនាហារពុទ្ធមាមកជនទាំងឡាយដែលមកពីទីជិតឆ្ងាយដោយឥតយកថ្លៃ ដើម្បីជាកិត្តិយសដ៏ឧឡារិកនៃបុណ្យបញ្ចប់ឆដ្ឋសង្គាយនាទីឯបុណ្យពុទ្ធជយន្តីនោះឯង ។

ចំណែកព្រះសង្ឃក៏ចេះតែនិមន្តមកគគ្រឹក ទាំងព្រះសង្ឃដែលគណកម្មការបុណ្យនិមន្តមកនិងព្រះសង្ឃក្រៅពីការនិមន្ត ។ ព្រះសង្ឃដែលគណៈកម្មការនិមន្តមកទទួលទេយ្យវត្ថុចំនួន ២.៥០០ អង្គ ដោយទីមហាគុហាទាំង ៤ ដាក់បានតែ ១.៥០០ អង្គ ទើបគណៈកម្មការរៀបមហាវិទ្យាល័យក្នុងក្រុងរ៉ង្គូន ដើម្បីព្រះសង្ឃ ១.០០០ អង្គទៀត ។ ប៉ុន្តែនៅតែខ្លះទីកន្លែងព្រះសង្ឃសឹងទៀត គណៈកម្មការក៏បានរៀបមហាគុហាទាំងបួននោះឲ្យសឹងក្នុងមួយបន្ទប់ ៤ អង្គ លើកតែមហាថេរដែលមានវស្សា ៤០ ឡើងទៅគេរៀបប្រគេនមួយបន្ទប់ ២ អង្គ ។

ក្នុងពេល អគ្គាសបង្ហាន់ក៏រៀបអគ្គាសជាពីរផ្នែកមួយផ្នែកនៅខាងឆដ្ឋសង្គាយនដ្ឋាន មួយផ្នែកទៀតនៅឯមហាវិទ្យាល័យនោះឯង ។ នៅពេលបុណ្យនោះពដការបានបញ្ចេញកងទ័ពជើងទឹកប្រមាណ ១.០០០ នាក់មកបំរើព្រះសង្ឃពេលតែពេលឆាន់ថ្ងៃនៅពេលរសៀលជួយសែងទេយ្យវត្ថុដែលពួក ឧបាសក-ឧបាសិកា អ្នកមានសទ្ធាជ្រះថ្លាប្រគេនលោកនៅក្នុងបាសាណគុហា ។

(នៅមាន ត)

តែឯព្រាយនៅប្រាង្គចេតិយធំទិសអាគ្នេយ៍នោះ មានពណ៌សម្បុរខៀវបានហោះមកផ្ទួលៗ តែមិនបានចូលមកក្នុងដែនសីមា ហើយក៏ហោះត្រឡប់វិលទៅប្រាង្គនោះវិញ ចាក់យកមិនបានសោះធ្វើតែយ៉ាងនេះពីរបីដង ព្រាយនេះរបឹងរឹងជាងព្រាយឯទៀត បានជាគាត់ប្រាប់ថាពូកែណាស់ប្រាង្គចេតិយធំនៅទិសអាគ្នេយ៍នោះ ។

នៅទិសខាងត្បូងចម្ងាយ ១០ ម៉ែត្រពីធឿនវិហារធំនេះមានអាស្រម១ខ្នង ដែលគេកសាងលើដីលើកខ្ពស់ប្រហែលជាកំពស់ ២ ម៉ែត្រកន្ទុះសម្រាប់ដំកល់ព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ដែលគេបានកសាងអំពីសិលាជាតិ ជាបាទលញ្ឆនៈស្នាមគំនូសចម្លាក់ប្រទាក់ដោយលក្ខណៈរូបផ្សេងៗ មានបណ្តោយជាង១ម៉ែត្រ ទទឹង១ម៉ែត្រ បិទមាសលាបជាតិជ័រហង្គុលគេលើកដំកល់ពានតាំង១ធំ ដែលគេធ្វើអំពីក្រាក់ខ្ចីមឈើទើទុកជាអនុស្សាវរីយ៍ជាទីធ្វើនមស្ការរបស់ពុទ្ធបរិស័ទ, នៅខាងក្រោយព្រះបាទនេះមានផែនថ្ម២ផ្ទាំង មួយផ្ទាំងបន្ទារសំប៉ែតធំពាងជាសីមា មួយផ្ទាំងទៀតជាផែន ៤ ជ្រុងស្មើកំពស់ប្រហែល ១ ម៉ែត្រ មានពណ៌សម្បុរខ្មៅដូចថ្មអណ្តើក(១)ហើយចារឹកសរសេរអក្សរខ្មែរទាំង ៤ ជ្រុងយ៉ាងស្អាតក្រៃលែង ជាគាថាភាសាបាលីសំស្ក្រឹតជាង ១០០ គាថា ដំណាលពីព្រះបាទជ័យវរ្ម័នទី ៥ ដែលទ្រង់បានរៀបចំកសាងដួសជុលព្រះពុទ្ធរូប និងទេវរូប ហើយបានដំកល់ទុកឲ្យមានរបៀបរៀបរយល្អតរៀងមកដល់សព្វថ្ងៃនេះ ។

តាមដំណឹងនិយាយតៗគ្នាមកថា: ព្រះបាទព្រះដែលគេបានដំកល់ទុកនូវទីចារឹកនោះ គឺព្រះបាទព្រះរបស់ព្រះចៅស្តេចលាវសម័យដើម ដែលទ្រង់បានចាត់ព្រះរាជបំរើឲ្យហែនាំយកព្រះបាទព្រះនេះ១ដើមជ្រៃលាប ដែលរលំស្លាប់ទៅជាយូរឆ្នាំហើយ ១

---

(១) ប្រហែលទៅឆ្នាំ ១៩៥២ មានចោរក្លាហានលបលួចទីនោះបាត់ទៅហើយ

មកថ្វាយជាធម្មបណ្ណាការ ទុកជាសក្ការៈគោរពបូជាចំពោះធម្មទេសនារបស់ព្រះមហា-ថេរ ១ អង្គជាជាតិក្សត្រិយ៍ទ្រង់ព្រះនាម អេគ្គ គេម, ដែលទ្រង់លះរាជសម្បត្តិចេញសាងផ្នួសជាបព្វជិតខំប្រព្រឹត្តរៀនធម៌ព្រះអភិធម្មទាល់តែចេះចាំស្ទាត់រត់មាត់ ហើយទ្រង់គង់ទេសនានៅវត្តឯកទេសដែលក្លាយយារមកហៅថា វត្តផ្នែកទេសន៍ ថ្វាយទៅព្រះចៅស្តេចស្រុកណោះ ព្រះចៅទ្រង់ជ្រះថ្លាដោយព្រះរាជសទ្ធាយ៉ាងខ្លាំង ទើបថ្វាយព្រះបាទព្រះនឹងដើមជ្រៃលាបនោះមកទុកជាអនុស្សាវរណីយវត្ថុរបស់ទ្រង់ ។

លុះកាលកន្លងទៅជាច់ស្រយាល នឹងរកមនុស្សណាម្នាក់សួរការណ៍ឲ្យអំពីលំដាប់ចៅអធិការវត្តព្រះរាជនិវេសន៍ផ្ទាននេះឲ្យពិតប្រាកដពុំបាន ទើបលោកព្រះគ្រូវិរិយមុនី សៅ-មៀច ដែលកើតនៅស្រុកនោះ បានដំណឹងជាកន្លះវាងជាង ១០០ ឆ្នាំកន្លងទៅហើយ ពួកយាយ-តា ដំណាលប្រាប់លោកថា: មានលោក ១ អង្គព្រះនាម ទេព ធ្វើជាចៅអធិការវត្តនេះ តពីសង្ឃរាជទេពនោះមក, លោកគ្រូព្រះនាម ស្រី ធ្វើជាចៅអធិការតពីលោកគ្រូព្រះនាមស្រីនោះមក លោកគ្រូព្រះហ៊ុន ធ្វើជាចៅអធិការ មានឋានាជាព្រះបាឡាត់គណៈដែលព្រះករុណាព្រះសុវណ្ណកោដ្ឋទ្រង់តាំងឲ្យ តពីលោកគ្រូ-ហ៊ុននោះមក លោកគ្រូព្រះនាម ទៀវ ធ្វើជាចៅអធិការ ។

វត្តនេះក៏ដល់នូវកាលធ្លាក់ចុះកិត្តិយសទន់ខ្សោយ ដោយមានបព្វជិតត្រឹមតែ ២-៣ ៤ អង្គប៉ុណ្ណោះ ព្រោះពុំមានការសិក្សាធម៌វិន័យដែលជាផ្លូវបំភ្លឺពន្យល់ដល់បព្វជិតទាំងនោះ ឲ្យបានចេះដឹងស្គាល់ផ្លូវប្រតិបត្តិជាដំណើរទៅកាន់សេចក្តីសុខ-ចំរើន ម៉្លោះហើយបព្វជិតទាំងនោះ វៀតបិតឃ្លាតចាកសេចក្តីប្រតិបត្តិធម៌វិន័យនឹងការចេះដឹង គេឃើញមានទីកន្ទ្រង់អយករណីកិច្ច នឹងរុក្ខករណីយកិច្ចកងទីវត្តជាច្រើន ឯពួកកុមារកូន

ទៅអ្នកស្រុកដែលគេយកមកទុកដាក់ធ្វើឲ្យរៀនសូត្រអក្សរសាស្ត្រនៅវត្ត មិនងាយនឹងរៀនឲ្យបានចេះដឹងច្បាស់លាស់ កំណត់កាលនៅត្រឹម៣-៤ឆ្នាំ ទើបចេះមើលសាស្ត្រា យល់សេចក្តីក្នុងរឿងនីមួយ ៗ តែបន្តិច នៅមិនទាន់ចេះសរសេរអក្សរប្រៀបរៀងសេចក្តីណាមួយឲ្យបានមធ្យមពុំទាន់កើត ហើយច្រើនតែមានអាយុ ១៦-១៧-១៨-១៩-២០ឆ្នាំទើបទៅនៅវត្តសិក្សារៀនអក្សរសាស្ត្រ ទាំងជួយធុរៈប្រកបការហាត់កម្មរបស់បព្វជិតទាំងនោះ, ចំណែកឯបព្វជិត រៀនបានតែធម៌មាតិកា ដែលពាក្យអ្នកស្រុកហៅថាធម៌ដារៈបុស្តកបវត្តិគឺធម៌សូត្រមន្ត បួសបានត្រឹម៣-៤វស្សាប៉ុណ្ណោះក៏លាចាកសិក្ខាបទទៅជាគ្រហស្ថរកស៊ីធ្វើស្រែចំការ ពុំសូវមានអ្នកបួសនៅរក្សាវត្តនោះច្រើនអង្គទេ ជួនកាលមានត្រឹមតែ ១ អង្គ ជួនកាលក៏ដាច់សូន្យគ្មានភិក្ខុអ្នកនៅគ្រប់គ្រងវត្តនោះសោះម៉្លោះ ហើយសេចក្តីបរិវត្តក៏កើតឡើងដល់ឧបាសក-ទាយកទាយិកា អ្នកកាន់ព្រះពុទ្ធសាសនា រិះរកនិមន្តលោកធ្វើជាអធិការដើម្បីរក្សាវត្តព្រះរាជនិវេសន៍នដ្ឋាននេះតអំពីលោកគ្រូចៅអធិការព្រះនាម ខៀវ នោះមកទៀត ។

កាលពុទ្ធសករាជ ២៤២២ គ្រិស្តសករាជ ១៨៨០ ពួកក្រុមឧបាសក-សិកាវត្តស៊ីធរបានរួមគំនិតគ្នា ចាត់ឧបាសកម្នាក់ មានឋានៈភ្នាក់ងារជាមេឃុំនៅឃុំស៊ីធរនេះឈ្មោះ (បញ្ញា-ចាប)ជាអ្នកមានសមត្ថភាពអង់អាច ហើយជាអ្នកឆ្លៀវឈ្លាសក្នុងធម៌វិន័យជាងមនុស្សក្នុងស្រុកទាំងអស់ ឲ្យគាត់ចូលមកកាន់សំណាក់សម្តេចព្រះមហាសង្ឃរាជព្រះនាម (ទៀង) នឹងព្រះតេជព្រះគុណព្រះមហាវិមលធម្មព្រះនាម (ថោង) ជាចាងហ្វាងទី១ នៃសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ សុំនិមន្តភិក្ខុ១រូប ឲ្យស័ក្តិសមទៅលួមធ្វើជាចៅអធិការវត្តស៊ីធរនោះបាន សម្តេចព្រះមហាសង្ឃរាជនឹងព្រះតេជព្រះគុណព្រះមហា

វិមលធម្ម ក៏បានចាត់ភិក្ខុ១រូបព្រះនាម (ល្វី-ឯម) ព្រះជន្មាយុ២១ឆ្នាំ ទើបនឹងបួសជាភិក្ខុកម្មោះថ្មី មានសរីរាយស្អាតសមសួនទាំងដងខ្លួនកំពស់កំពារមើលទៅមិនទាស់ភ្នែក, លោកតា (បញ្ញា-ចាប) គ្រាន់តែក្រឡេកឃើញភិក្ខុ (ល្វី-ឯម) និមន្តមកថ្វាយបង្គំព្រះមហាវិមលធម្ម (ថោង) គាត់ក៏ត្រេកអរអស្ចារ្យក្នុងចិត្តគិតថា: អើះ! លោកនេះជាអ្នកប្រាជ្ញមុខជានឹងចេះដឹងធម៌វិន័យពិតប្រាកដឥតសង្ស័យ ព្រោះគាត់ជាអ្នកប៉ិនខាងស្គាល់លក្ខណៈសម្បត្តិ គិតថា: ក្មេងក៏ក្មេងប៉ុះ! ព្រោះមិនខុសពីចិត្តរបស់អញ គាត់មានសេចក្ដីសោមនស្សរីករាយ បានទទួលនិមន្តភិក្ខុ (ល្វី-ឯម) អំពីសំណាក់សម្ដេចព្រះមហាសង្ឃរាជនឹងព្រះតេជព្រះគុណព្រះមហាវិមលធម្ម ឲ្យទៅធ្វើជាចៅអធិការវត្តស៊ីធរ តពីលោកគ្រូចៅអធិការព្រះនាម ខៀវ នោះមក ។

ភិក្ខុ (ល្វី-ឯម) បានទទួលនាទីធ្វើជាចៅអធិការវត្តព្រះពជនិវេសនដ្ឋានស្រីសឈរបីនួន១៣ឆ្នាំ បាននាមបញ្ញត្តិជាព្រះគ្រូវិមលបញ្ញា រឿនហ៊ានក្រសួងសង្ឃ ដោយអំណាចសម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង ប្រទានថានៈជា ព្រះគ្រូវិមលបញ្ញា (ល្វី-ឯម) ចៅអធិការវត្តស៊ីធរ មានកិត្តិស័ព្ទល្បីល្បាញខាងការសំដែងធម៌ទេសនាជាវោហារកោសល្យផង ខាងការបង្ហាត់បង្រៀនព្រះបរិយត្តិធម៌ ពីត្រៃបិដកផង ខាងការបង្ហាត់ធម៌សូត្រឲ្យត្រឹមត្រូវតាមផ្លូវសំយោគគឺសង្កត់ឲ្យល់ទប់បង្អង់បន្ដិចត្រង់អក្ខរៈណាដែលមានគុរុព្យញ្ជនៈជម្រុតគ្នាឲ្យរត់មាត់ជាពួនមួយមិនឲ្យរអាក់រអួលផង ទាំងបង្រៀនអក្សរសាស្ត្រដល់ពួកកុមារដែលមកនៅសិក្សាផ្ទាល់ នឹងចាត់ការរៀបចំវត្តអារាម ឲ្យបានរុងរឿងផង ដូចមានករណីយកិច្ចដែលយើងបានពោលរៀបរាប់តទៅនេះ

(នៅមានត)

# ធនញ្ជយបណ្ឌិត (ត)

លុះព្រឹកឡើងព្រះរាជាឡើងគង់លើខ្នងហត្ថីបរចេញទៅតាមទ្វារកំផែងខាងកើត ៗ ឯអស់ពួកមន្ត្រីតូចធំនឹងស្រីស្នំក្រមុំទាំងឡាយមាននាងអតុលាទេវីជាដើម ដែលជាចម្បងលើស្រីមួយម៉ឺន៦ពាន់រូប មានសេចក្តីមេត្តាករុណាភិតភ័យអាឡោះអាល័យសោកស្តាយព្រះរាជានាំគ្នាសំរក់ទឹកភ្នែកស្រែកទ្រហោទួញយំដំនុរ៉ា រំសាយសក់យំបំរះនរទៀលទឹងដីដើរតាមព្រះរាជាទៅ ៗ ឮស្សូរតែសំឡេងយំទួយទ្រហឹងអឹងកង ដូចផ្គរលាន់ខែដើមឆ្នាំនោះឯង ៗ តស្មឹ ខណេ ពោធិសត្តោ ធនញ្ជយកុមារោ ឯវំ សទ្ទំ សុត្វា ក្នុងគ្រានោះធនញ្ជយកុមារដែលជាអង្គពោធិសត្វឮស្សូរសំឡេងយំយែកប៉ូកអស្ចារ្យយ៉ាងនេះហើយ ក៏សួរធនញ្ជយសេដ្ឋីជាបិតាថា “ចុះឮសន្ធឹកអ៊ូខ្ញាំងម្ល៉េះលោកឪពុក”? ឱ ! កូនប្រុសអើយមិនដឹងទេឬ? ព្រះករុណាជាម្ចាស់ជីវិតរបស់យើងព្រះអង្គមានទុក្ខធំណាស់កូន ! ដៀតដល់ថ្ងៃសន្មត ស្តេចយាងទៅឲ្យយក្សស៊ីថ្ងៃហ្នឹងហើយកូន ! បានជាមហាជនទាំងអស់យំស្តាយព្រះអង្គជាម្ចាស់ផែនដីដូច្នេះ ៗ

បើតបឹងខ្ញុំសូមទៅមើលគេបន្តិច ពោធិសត្វក៏ស្ទុះទៅ ៗ ឈរពាំងពីមុខហត្ថីព្រះទីនាំងហើយថ្វាយបង្គំប្រណម្យអញ្ជលី ក្រាបទូលសួរថា បពិត្រព្រះនរបតីស្រីសម្មតិទេពក្យក្រថ្ងៃប្រសើរជាអម្ចាស់ជីវិតលើត្បូង ព្រះអង្គមានហេតុទុក្ខភ័យដូចម្តេចព្រះអង្គ? ស្តេចក៏ទ្រង់ឆ្លើយតបទៅវិញថា: “អើ ! ចៅអើយយើងមានទុក្ខធំណាស់យក្សវាចាប់យើងពី៧ថ្ងៃមុនវាប្រុងនឹងសម្លាប់បរិភោគជាអាហារទៅហើយ ៗ វាសួរមកយើងថា តើមានចេះមលគរធម៌ដែរឬទេ? បើពុំចេះទេវានឹងចាប់បរិភោគជាចំណីអាហារ ទើបយើងសូមអង្វរភរយក្សមករកអ្នកប្រាជ្ញដែលចេះមលគរធម៌នោះឲ្យវាអស់ ៧ ថ្ងៃ ឥឡូវនេះរកមិនបាន

សោះឡើយ  បានជាយើងត្រូវទៅឲ្យយកក្របីគោខ្លួនឯង» ។  «បើដូច្នោះទូលព្រះ
បង្គំសូមទៅជំនួសព្រះអង្គ» ។  «ចៅឯងឈ្មោះអ្វី? នៅឯណា? ចេះមលតរធម៌
ដែរ...?»  «ក្រាបទូលឈ្មោះធនញ្ជយកុមារ  បុត្រនាងសុខមាលីជាភរិយាធនញ្ជយ-
សេដ្ឋី  បុគ្គលក្នុងភពលោកក្រៅពីទូលបង្គំចេញ ឥតមាននរណាចេះទេ  មានតែព្រះ
ពុទ្ធទើបជ្រាបបាន ។  ដូច្នេះសូមសំលៀកបំពាក់សសុទ្ធប្រទានដល់ខ្ញុំព្រះអង្គ» ។
ស្តេចទ្រង់លើកព្រះពោធិសត្វដាក់លើទីនាំងហត្ថីទន្ទឹមនឹងព្រះអង្គ ។  កាលណោះ
ធនញ្ជយសេដ្ឋីនឹងនាងសុខមាលី ស្ទុះទៅឃាត់ព្រះពោធិសត្វថា  កុំទៅអីកូនខ្លាចយក្ស
វាធំណាស់កូនឯងនៅតូចណាស់  វាស៊ីមិនស្កៀមដើងធ្មេញទេ  ន៎! កូនកុំឲ្យទ្រូង
ម្តាយផ្សាក្តៅ  លាព្រះអង្គចុះពីហត្ថីវិញមកកូន! ។  ទើបព្រះពោធិសត្វទ្រង់សំដែង
ធម៌ឲ្យមាតាបិតាជ្រះថ្លាពេញទៅដោយសោមនស្សរីករាយ  ដោយសេចក្តីឧបមាថា: ដូច
ជាសមុទ្រសាគរទុកណាជាមានខ្យល់ព្យុះបក់បោកយ៉ាងណា  ក៏មិនអាចធ្វើទឹកសមុទ្ទសា-
គរឲ្យរើងហួតបានឡើយ  ខ្លួនខ្ញុំជាកូនតែងប្រកបដោយព្រហ្មវិហារផ្សាយទៅក៏យ៉ាង
នោះដែរ  ពុំនោះសោតដូចជាព្រះអាទិត្យ  បើទុកជាពពកអាសូរិន្ទមកបៀតបៀនយ៉ាង
ណាក៏មិនបញ្ឈប់ដំណើរដើរត្រឡែងពន្លឺពិភពលោកជាធម្មតា, ខ្លួនខ្ញុំឯងក៏យ៉ាងនោះដែរៗ
មាតាបិតាពោធិសត្វកាលបើឃាត់ពោធិសត្វជាបុត្រមិនបានដូច្នោះហើយ  ក៏សូត្រមន្តឲ្យ
ពរថា: «បិយ បុត្តក សព្វ សោត្ថិ សព្វ សុទ្ធិ សព្វ ជយោ ភវតុតេ  ម្នាលកូន
ស្ងួនសំឡាញ់អើយ  សេចក្តីសួស្តីទាំងពួងក្តី  សេចក្តីសម្រេចសម្រិទ្ធិជោគសព្វយ៉ាងក្តី
ជោគជ័យឈ្នះមារសត្រូវទាំងពួងក្តីចូរឲ្យមានដល់កូនចុះ» ។  រួចក៏ត្រឡប់ទៅកាន់គេ-
ហស្ថានវិញ  ទាំងពីរនាក់ទៅហោង ។

គ្រានោះព្រះបាទកោរព្យរាជ គៀកធនញ្ជយកុមារឡើងគង់លើខ្នងហត្ថីទន្ទឹមគ្នា ហើយបរសំដៅទៅដើមជ្រៃនោះ លុះមើលឃើញដើមជ្រៃលិម ៗ ហើយស្តេចបង្អុលបង្ហាញពោធិសត្វថា នុះហ្ន៎! ចៅ! ជ្រៃហ្នឹងហើយ ចូរចៅទៅតែម្នាក់ឯងចុះ ៗ ស្តេចព្រមទាំងបរិពារក៏ឈប់ពួននៅទីនេះទាំងអស់គ្នា ៗ ពោធិសត្វជាកុមារតូចជិះលើហត្ថីស្ទើរតែមើលមិនឃើញ បរចូលទៅបានដល់ដើមជ្រៃនោះស្រែកហៅយក្សថា អឺ នន្ទិយក្ស! យើងមកដល់ហើយ! ៗ ៗ នន្ទិយក្ស ជាអទិស្សមានកាយទេ លុះឮពាក្យសំដី ធនញ្ជយកុមារហៅខ្លួនដូច្នោះក៏កើតចិត្តស្រឡាញ់ស្នេហាដូចជាកូនកើតពី-សាច់យ៉ាងនោះ ក្លែងខ្លួនឲ្យឃើញប្រាកដហើយសួរថាៈ — ភោ .មាណវ ម្នាលមាណពដ៏ចំរើន! អ្នកឈ្មោះអ្វី„? —«កូននរណា?„ មានការអ្វី?— នរណាបញ្ជូនអ្នកមក? ពោធិសត្វតបថា «យើងឈ្មោះធនញ្ជយកុមារ ជាបុត្រធនញ្ជយសេដ្ឋី ជាទាសបុត្រនៃព្រះបាទធនញ្ជយកោរព្យរាជ ព្រះអង្គបញ្ជូនយើងមកបានជាយើងមកដូច្នេះៗ —«ចុះមាណពឯងចេះមលតរធម៌ដែរ ឬ?„ ៗ —«អ្នកឯងដឹងហើយតើយើងនេះស្តេចបញ្ជូនមកឲ្យអ្នកឯងបរិភោគជាចំណីអ្នក„ ៗ —«ទេ!... សាច់ទងឈាមរបស់អ្នកតូចណាស់ មិនស្កប់ទឹងពេញខ្ញុំទេ យើងមិនស៊ីអ្នកឯងឡើយ មកចូលមកចុះ„ ៗ ពោធិសត្វចូលទៅក្រោមម្លប់ជ្រៃហើយឈរស្ងៀម ៗ —«ម្តេចក៏មាណពឯងមិនចូលឲ្យដល់យើងមក„? —«យើងកាន់សុចរិតធម៌បានជាមិនចូលដល់អ្នក!„ —យី!.. ដូចម្តេចទៅសុចរិតធម៌សូមមាណពឯងថែងបន្តិចមើល? ៗ អ្នកចាំស្តាប់ចុះដូច្នេះថាៈ

អនិមន្តំ យំ គន្ត្វា អបុច្ឆា បរិភាសតិ អត្តានញ្ច បសំសិយោ តំវិធហី-នលក្ខណំ សេចក្តីថា កិរិយាខាត លក្ខណ៍មាន ៣ យ៉ាងគឺៈ គេមិនទាន់និមន្ត ឬអញ្ជើញឲ្យទៅផ្ទះគេហើយទៅកាន់ផ្ទះគេញយ ១, គេមិនទាន់សួរតាំងឆ្លើយស្រាវមុន១,

គេមិនទាន់សរសើរតាំងអួតសរសើរលើកគុណខ្លួនឯង១, ម្នាលយក្ស បុគ្គលលុះតែលះបង់ហិនលក្ខណៈទាំងបីនេះចេញឲ្យស្រឡះទើបឈ្មោះថា អ្នកប្រព្រឹត្តធម៌សុចរិតពិតមែន ” ។

យក្សស្តាប់ហើយនឹកស្ញើចក្នុងចិត្តថា នេះបានជាបុរសអាជានេយ្យពិតប្រាកដមែន ទើបមានវាចាថា: “ខ្ញុំមិនដែលឮទេ ពីរោះណាស់ ខ្ញុំសូមបូជាដោយគ្រឿងសក្ការៈដល់អ្នក ហើយរៀបគ្រែធម្មាសនៈនឹងសក្ការៈជាច្រើន មានទាំងស្លត្រង់គ្រប់ទបាំង ហើយក៏ម្នីម្នាហោះស្ទុះទៅដងទឹកអនោតត្តស្រះផ្ងូតជំរះកាយព្រះពោធិសត្វ ប្រស់ព្រំដោយគ្រឿងក្រអូបឈ្ងុយឈ្ងប់ទាំងចំណីជាទិព្វ ប្រដាប់ដោយគ្រឿងអលង្ការល្អស្អាត ទើបអារាធនាអញ្ជើញព្រះពោធិសត្វឡើងលើធម្មាសនៈ សំដែងធម៌ទេសនា អំពីមលគរធម៌នោះ ។

ព្រះពោធិសត្វក៏តាំងចាប់យកផ្ចិតបទមុខប្រកាសឲ្យយក្សទទួលកល្យាណធម៌ជាមុនថា: គោ យក្ខរាជ ! ម្នាលស្តេចយក្ស ! អ្នកឯងប្រុងចាំទទួលកល្យាណធម៌ជាបទគាថាដូច្នេះថា:

បាណាតិបាតា ធនហារតោ បរស្សទានំ វចនំ អសច្ចំ មជ្ជំ វិយោ ឥធសោ នរោច បមូលច្ឆេទោ មុនិនា បវុត្តោ ។ សេចក្តីថា បុរសស្ត្រីណាក្នុងលោកនេះប្រព្រឹត្តសម្លាប់សត្វ១ លួចប្លន់ បំបាត់ប្រវ័ញ្ចនបន្ទំ បោកបញ្ឆោតយកទ្រព្យគេ១ លួចប្រពន្ធគេ លួចប្តីគេ លួចកូនក្រមុំគេ១ និយាយកុហក១ ផឹកសុរា-មេរ័យ គឺស្រា-ទឹកត្នោតជូ អាភៀនកញ្ឆាជាដើម១ នរណាប្រព្រឹត្តធ្វើអំពើទាំង៥នេះ ឈ្មោះថាជីករំលើងឫសគល់ខ្លួនឯងលែងបានកើតជាមនុស្សទៅទៀតហើយ នេះជាធម៌លាមកក្រៃលែង ។ (នៅមានត)

# ជ័យប្រាជ្ញ (ត)

ព្រះមហាក្សត្រ តើអ្នកភ្នាល់គ្នាព្រមសុខចិត្តចាញ់ទេ ដូចសំដីដើមរបស់អ្នកភ្នាល់គ្នា ឬមិនព្រម ។

ពួកអាមាត្យ នៅទ្រឹងមួយសន្ទុះហើយ នឹកក្នុងចិត្តថា បើឯងព្រមទទួលយកក៏ចាញ់វា បើមិនព្រមទទួលយកក៏ចាញ់វា ណ្ហើយចុះសព្វបើគ្រាន់តែការសុំចាញ់ប៉ុណ្ណោះ ត្រូវតែព្រមព្រោះថាបើទុកជាយើងព្រមសុខចិត្ត ក៏វានឹងធ្វើអីយើងមិនកើតដែរ ខ្មោចអាក្មេងប្រមក់ប៉ុណ្ណោះ ។

លុះគិតដូច្នេះហើយ អាមាត្យទាំងឡាយ ក្រាបបង្គំទូលទៅព្រះមហាក្សត្រវិញថា សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំទាំងអស់គ្នាព្រមទទួលយកការសុំចាញ់ទេនោះ តាមសំដីដើមហើយ ។

ព្រះមហាក្សត្រ ! អើ ! អាជ័យ ! ឥឡូវនេះគេព្រមទទួលហើយ តើអាឯងគិតធ្វើដូចម្ដេច ។

កុមារជ័យ សូមទ្រង់ព្រះមេត្តាប្រោស ! បើអស់លោកព្រមទទួលយកការសុំចាញ់ទេមែន ទូលព្រះបង្គំសុំបញ្ជាក់តទៅទៀតថាត្រង់ពាក្យអស់លោកថា “ចាំមើលពេលក្រោយបើព្រះមហាក្សត្រត្រាស់ហៅអាឯងឲ្យចូលមកទៀត នោះយើងប្រាកដជាសុំចាញ់អាឯងតែម្ដង„ ។ ឥឡូវនេះអស់លោកសុំចាញ់ទេ ពាក្យនេះនឹងរើរុះមិនបានៗ

អម្បាលមិញនេះ ទូលព្រះបង្គំចេញទៅដល់ខាងក្រៅព្រះបរមរាជវាំងហើយ ព្រះករុណាថ្លៃវិសេសទ្រង់ត្រាស់ឲ្យហៅចូលមកវិញ ក្រោយកិច្ចសន្យារបស់អស់លោកនឹងទូលព្រះបង្គំនេះ តើឈ្មោះថាព្រះអង្គទ្រង់ត្រាស់ឲ្យហៅទូលបង្គំចូលមកទៀតឬទេ ? ។

ព្រះមហាក្សត្រ យ៉ាងនេះពិតជាអញឲ្យហៅអាឯងចូលមកទៀត អ៊ុចឹងមែនហើយ ។

កុមាជ័យ បើដូច្នោះ តើត្រូវពួកអស់លោកទទួលយកការសុំចាញ់ទេឬយ៉ាងណា?។

ព្រះមហាក្សត្រ ត្រូវតែពួកអ្នកទាំងនេះ ទទួលយកការសុំចាញ់ទេនោះអ៊ុចឹងហើយ ។

កុមារជ័យ នែ! អស់លោកដូចម្ដេច ដែលគេហៅថាចាញ់ទេ ។

ពួកអាមាត្យ ដែលគេហៅថាចាញ់ទេ គឺចាញ់ឥតមានជាក់អ្វីសោះ ។

កុមារជ័យ អ៊ីចឹងមែនហើយលោក ឯចាញ់ទេ គឺចាញ់ឥតមានរឿងហេតុអ្វីសោះ ដូចជាបានទទេនោះដែរ ។ ដូច្នេះតាំងពីថ្ងៃនេះទៅ ត្រូវតែអស់លោកសុំចាញ់ខ្ញុំ ទើបទុកជាការត្រឹមត្រូវបាន បើត្រឡប់ជាមិនចាញ់វិញ នោះទុកជាកុំហុសមួយយ៉ាងធំ ។

ព្រះមហាក្សត្រ ទ្រង់ព្រះសម្រួល ហើយមានព្រះបន្ទូលថាអ៊ីចឹងមែនហើយ ពួកអាមាត្យក្ដើមុខក្រៀមទាំងអស់គ្នា ។ កុមារជ័យក្រាបបង្គំលាព្រះមហាក្សត្រចេញទៅកាន់ផ្ទះរបស់ខ្លួនតាមប្រក្រតី ។

តាំងពីថ្ងៃនោះមកកុមារជ័យចេះតែដើរនិយាយប្រាប់អ្នកស្រុកអ្នកភូមិថា ពួកសេវមាត្យចាញ់ខ្ញុំទាំងអស់ គ្មាននរណាឈ្នះខ្ញុំម្នាក់សោះ ខ្លួនឯងឈ្មោះជ័យហើយ បានជ័យទៀត នេះហៅថាជ័យត្រួតលើជ័យ ។

ពាក្យនោះឮរន្ទឺពេញព្រះរាជធានីទាំងមូល ល្បីថាកុមាជ័យឈ្នះអាមាត្យទាំងអស់ ៗ អ្នកខ្លះនឹកឆ្ងល់ថា អាជ័យនេះវាឈ្នះពីរឿងអី ហើយទៅសួរពួកអាមាត្យខ្លះៗក៏ឆ្លើយប្រាប់មកវិញថា ណ្ហើយកុំបាច់សួរពីរឿងអាជ័យនោះធ្វើអី គ្មាននរណានិយាយជាមួយនឹងវាបានទេ ស្រេចតែនឹងវាថាដូចម្ដេចក៏ថាទៅ

ថ្ងៃក្រោយមកពួកអស់អ្នក នឹងពួកសេវកាមាត្យដង្ហែព្រះមហាក្សត្រកាត់ក្ដីទៅទីផ្សារ ។ ថ្ងៃនោះឯកទឹងកាណាទៅវាល កុមារជ័យបានក្រឡេកមើលទៅឃើញដង្ហែព្រះមហាក្សត្រមកពីចម្ងាយ ហើយរត់ឡើងមកលើផ្ទះ យកកំបោរលាបគូថហើយគូរធ្វើជាមុខ ។ គ្រាន់តែព្រះមហាក្សត្រទ្រង់យាងហួសផ្ទះខ្លួនបន្តិចទៅក៏ទយគូថតាមប្រហោងជញ្ជាំងមកក្រោម ។ ពួកអស់អ្នកក្រឡេកមើលទៅឃើញមុខស្រមាមចេញក្ដែតមកដូច្នោះ ក៏នាំបន្អុលខ្ទាត់ខ្លួនមាត់អ៊ូអរឡើងថា សត្វអីនោះៗ លោតែចេញក្ដែតមកតាមប្រហោងជញ្ជាំងផ្ទះអាជ័យ មុខស្រមេមស្រមាមយ៉ាងនេះ សេចក្ដីច្រួលច្របល់នេះផ្អើលដល់អាមាត្យឮដល់ព្រះមហាក្សត្រៗក៏ទ្រង់ត្រាស់ឲ្យអាមាត្យឡើងទៅមើល

ពួកអាមាត្យបានឡើងទៅមើលឃើញកុមារជ័យឱនទយគូថតាមប្រហោងជញ្ជាំងក៏ចុះមកក្រាបបង្គំទូលព្រះមហាក្សត្រវិញ តាមដំណើរនោះ ។ ព្រះមហាក្សត្រទ្រង់សណ្ដាប់ហើយកំណត់ក្នុងព្រះទ័យទើបស្ដេចយាងហួសទៅ ។

លុះស្ដេចយាងត្រឡប់មកដល់ព្រះបរមរាជវាំងវិញ ទ្រង់ត្រាស់ប្រើអាមាត្យឲ្យទៅហៅកុមារជ័យមកដល់ហើយ ទ្រង់មានព្រះបន្ទូលសួរថា នែ! អាជ័យ! ហេតុអ្វីក៏អាឯងគូរក្របេះគូថទយតាមប្រហោងជញ្ជាំងបង្ហាញអញយ៉ាងនេះ ។

កុមារជ័យ.— សូមទ្រង់ព្រះមេត្តាប្រោស! កាលដែលព្រះអង្គស្ដេចយាងដល់ផ្ទះទូលព្រះបង្គំ ទ្រង់បានងៀងព្រះនេត្រទតផ្ទះទូលព្រះបង្គំដែរឬទេ ?

ព្រះមហាក្សត្រ.— អញក្រឡេកមើលទៅដែរ ។

កុមារជ័យ.— ចុះព្រះអង្គបានឃើញទូលព្រះបង្គំធ្វើដូច្នោះឬមិនឃើញ ។

ព្រះមហាក្សត្រ.— អញមិនឃើញទេ ។

កុមារជ័យ.– បពិត្រមហាពជ! បុះអ្នកណាឃើញទូលព្រះបង្គំធ្វើដូច្នោះ ។

ព្រះមហាក្សត្រ.– អញមិនដឹងជាអ្នកណាឃើញដែរ ស្រាប់តែពួកមាត់អ្នកឡើង ទើបអញប្រើសេវកាមាត្យឲ្យទៅមើល ។

កុមារជ័យ.– បើដូច្នោះ សូមព្រះអង្គត្រាស់ហៅអ្នកទាំងអស់នោះមក ហើយ មានព្រះបន្ទូលសួរមើល តើអ្នកណាបានឃើញមុនគេ ។

ព្រះមហាក្សត្រទ្រង់ត្រាស់ឲ្យហៅពួកសេវកាមាត្យទាំងនោះមកហើយ ទ្រង់ត្រាស់ សួរហូរហែរទៅឃើញថា ពួកអស់អ្នកឃើញមុនគេ ទើបទ្រង់មានបន្ទូលសួរទៅកុមារ ជ័យថា នែ! អាជ័យ! ឥឡូវនេះពួកអស់អ្នកគេឆ្លើយថា គេឃើញមុនគេ ។

កុមារជ័យ.– បពិត្រ! ព្រះសម្មតិទេព សូមទ្រង់ចាត់វិធានការឲ្យស្បថជាមុនសិន សឹមឲ្យឆ្លើយរៀបរាប់អំពីការឃើញនូវអំពើរបស់ទូលព្រះបង្គំ ទើបចម្លើយនោះទៀងត្រង់ៗ

ព្រះមហាក្សត្រ.– បើដូច្នោះ ត្រូវអ្នកទាំងអស់ទៅធ្វើសម្បថ បំពោះមុខអ្នកតា ដំបងដែក ឯដើមប្រៃជ្រៃនោះសិនទើបមកឆ្លើយបញ្ជាក់បាន ចំណែកខាងអាជ័យវិញ ក៏ ស្បថដែរ ។

ពួកសេវកាមាត្យ ទាំងពួកអស់អ្នក នាំគ្នាទៅស្បថចំពោះមុខអ្នកតាដំបងដែក ឯ ដើមប្រៃជ្រៃនោះ កុមារជ័យក៏ទៅស្បថជាមួយនឹងគេដែរ ។

ក្រោយពេលដែលស្បថហើយ ក៏នាំគ្នាចូលមកគាល់សំណាក់ ព្រះមហាក្សត្រ ។ ទ្រង់ត្រាស់សួរបញ្ជាក់ទៅពួកអស់អ្នកអំពីដំណើរដែលឃើញតើមានសភាពយ៉ាងណា? ។

ពួកអស់អ្នកក៏បានក្រាបបង្គំទូលតាមពិតថា បពិត្រព្រះសម្មតិទេព នៅវេលាដែល ទ្រង់ស្តេចយាងហួសបន្តិចទៅ ស្រាប់តែទូលព្រះបង្គំឃើញមុខស្រមេមស្រមាមចេញ ក្លែតតាមប្រហោងជញ្ជាំងផ្ទះអាជ័យ ទូលព្រះបង្គំនឹកភ័យភ្ញាក់មាត់ភ្ញាក់កឡើងមួយរំពេច

នោះ ព្រោះតែគ្រង់ខ្លាចលង់តាំងពីថ្ងៃ លុះឮដល់ពួកសេវកាមាត្យៗ ក៏ក្រាបបង្គំទូលព្រះអង្គៗ ក៏ទ្រង់ចាត់ការឲ្យទៅមើលឃើញពិត ហើយនាំសេចក្ដីមកក្រាបបង្គំទូលវិញ ។

ព្រះមហាក្សត្រ នែ ! នាយ ! ដែលអញប្រើឯងឲ្យឡើងទៅមើលនោះឯងឃើញពិតជាអាជ័យវាធ្វើដូច្នោះមែន ឬ? ។

ពួកសេវកាមាត្យ សូមទ្រង់ព្រះមេត្តាប្រោស ឃើញអាជ័យវាធ្វើដូច្នោះមែន ។

ព្រះមហាក្សត្រ ចុះអាជ័យ ! ឯងធ្វើដូច្នោះមែន ឬ? ។

កុមារជ័យ សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំបានធ្វើដូច្នោះមែន ។

ព្រះមហាក្សត្រ អាឯងធ្វើយ៉ាងនេះដោយមានបំណងយ៉ាងណា ។

កុមារជ័យ សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំមានចិត្តរលឹកព្រះអង្គ, នឹងរលឹកពួកសេវកាមាត្យ, នឹកមានចិត្តនឹករលឹកអ្នកបងទាំងអស់ពន់ពេក ។ លុះទ្រង់ស្ដេចយាងមកដល់ផ្ទះទូលព្រះបង្គំលបែរមើលតាមប្រហោងតូចនៃជញ្ជាំងផ្ទះ ។ កាលទ្រង់ស្ដេចយាងផុតទៅភ្លាម ពួកអស់អ្នកទាំងនេះមកដល់ទូលព្រះបង្គំមិនហ៊ានអើតមុខមើល ព្រោះកាលពីថ្ងៃមុន បានស្រដីចំពោះទូលព្រះបង្គំថា ស្អប់មុខអាជ័យណាស់ៗ កាលណោះទូលព្រះបង្គំបានបញ្ឈក់ទៅអ្នកបងទាំងនោះវិញថា បើប្រាកដជាស្អប់មុខមែន នឹងមានការធ្វើខ្ទមខ្ញុំ ព្រោះតែស្អប់មុខនោះឯង ហេតុនេះបានជាទូលព្រះបង្គំគួរក្រពីងតូចធ្វើជាមុខទទួលមើលអ្នកបងទាំងអស់នោះ តាមប្រហោងជញ្ជាំង ព្រោះមិនហ៊ានបង្ហាញមុខ ក្រែងអ្នកបងស្អប់មុខដូចមុនទៀត ។

ព្រះមហាក្សត្រ លុះទ្រង់ព្រះសណ្ដាប់សេចក្ដីក្រាបបង្គំទូលនៃកុមារជ័យយ៉ាងនេះ ទ្រង់ត្រាស់សួរបញ្ឈក់ទៅពួកអស់អ្នកទាំងនោះវិញថា នាងទាំងឡាយបាននិយាយដូច្នោះមែនឬ? ។ (នៅមានត)

# ពាក្យថ្មីរបស់គណកម្មការវប្បធម៌ ដែលប្រែចេញពីភាសាបារាំង

| | |
|---|---|
| Jumenterie des F.A.R.K. | ទីបង្កាត់សេះនៃ ស.ខ.ក. |
| Jeunesse | យុវភាព |
| Jurés | មេប្រយោគ |
| La boratoire micrologie | ទីពិសោធន៍អតិសុខុមជីវសាស្ត្រ |
| Lauréats | ជ័យលាភី |
| Lettre de change | រូបិយាណត្តិ លិខិតដែលឈ្មោះកបង្គាប់ ឈ្មោះ ខ ឲ្យបើកប្រាក់ឲ្យឈ្មោះ គ |
| Lettre valant marché | សមាគមលិខិត |
| Libollé des opérations | រាយរាប់ប្រតិបត្តិការ |
| Linguistique général | ភាសាសាស្ត្រទូទៅ |
| Livre auxiliaire | សៀវភៅជំនួយ |
| Livre de compte | សៀវភៅគណនី |
| Livre journal | សៀវភៅប្រចាំថ្ងៃ |
| Logique | តក្កវិជ្ជាតក្កវិទ្យា |
| Main d'œuvre | ហត្ថពល-ហត្ថព-លិត-ហត្ថមូល |
| Marche | យាត្រា |
| Marché | ផ្សារ អាបណសញ្ញា សញ្ញាលក់ទិញ |
| Maréchél jerrant | ជាងបោះក្របកសេះ |

| | |
|---|---|
| Maréchalerie | រោងជាងដោះក្រចកសេះ |
| Médecinchef | គ្រូពេទ្យនាយ |
| Médecintraibent | គ្រូពេទ្យព្យាបាល |
| Miss combodge | បវរកញ្ញាកម្ពុជា |
| Monument | វិមាន |
| Norme | ធម្មនិយាមបង្គួនគោលការដែលទុកជាវិធាន |
| Nomade | អ្នកសាត់អណ្តែត |
| Notice | និវេទន៍-វិញ្ញាណប័ន |
| Notification | ប្រវេទន៍ វិញ្ញាប័ន-វិញ្ញាត្តិ ការឲ្យដំណឹង ជាលាយលក្ខណ៍អក្សរ |
| Nouvelle | ប្រតិបត្តិការ ដំណឹង |
| Office national des changes | ជាតិមន្ទីរប្តូរប្រាក់ |

---

## រចនាវិលាសវាក្យភាសាអង់គ្លេស (ត)

| | |
|---|---|
| 1 -They coudn't (ឃូដ-ដឹនត៍) pay the rent, so the landlord TURNED THEM OUT. | អ្នកទាំងនោះពុំអាចចេញថ្លៃឈ្នួលបាន, ព្រោះហេតុនោះត្រូវម្ចាស់ផ្ទះដេញចេញ ។ |
| 2- It was cloudy this morning, | ព្រឹកនេះមេឃងងឹត, ប៉ុន្តែត្រឡប់ |

but it TURNED OUT fine. — ជាស្រឡះឆេញទៅវិញ ។

3- Althongh it looked like rain this morning, il TURNED OUT to be a fine 'day. — សូម្បីហាក់ដូចជារកកល់ភ្លៀងព្រឹកនេះ, វាបានត្រឡប់ទៅជាស្រឡះឆេញទៅវិញ ។

4- Hari has TURNED OUT to be the best student in our English class, — កុមារ ហារី បានត្រឡប់ទៅជាសិស្សពូកែឆ្នើម ក្នុងថ្នាក់រៀនអង់គ្លេសរបស់យើង ។

5- She TURS OUT one room every day. — នាងនោះតែង បោសសំអាតបន្ទប់មួយរាល់ៗថ្ងៃ ។

VII- TO TAKE INTO ACCOUNT; (to take into consideration) — លើកយកមកពិចារណា;

1- In judging her work, you should TAKE INTO ACCOUNT that she has been quite sick recently. — ក្នុងការជំនុំជំរះនូវកិច្ចការរបស់នាង, គួរលោកលើកយកមកពិចារណា នូវហេតុថា នាងបានឈឺធ្ងន់ក្នុងពេលថ្មីៗនេះ ។

2- He never TAKES INTO ACCOUNT the faet that I am very busy. — វាមិនដែលលើកយកមកពិចារណា នូវសេចក្ដីពិតថា ខ្ញុំជាអ្នករវល់ខ្លាំង (ដូច្នេះសោះ)

VIII- TO SMELL; (to have bad ordour; to perceive any ordour) — មានក្លិនអាក្រក់; ហិតក្លិន; ធុំក្លិន;

1- Take that cheese away, it SMELLS.

យកព្រហក់បារាំងនោះចេញ, វាធុំក្លិនអាក្រក់ (ស្អុយ) ។

2- I woke up with a start, I coule SMELL fire.

ខ្ញុំស្ទុះក្រោកឡើង, ខ្ញុំធុំក្លិនភ្លើងឆេះ ។

NOTE: ពាក្យ «smell» បើប្រើចំពោះក្លិនអាក្រក់ មិនបាច់បញ្ចូលពាក្យដទៃមកជាជំនួយក៏បាន ព្រោះពាក្យនេះអាចឲ្យអត្ថន័យថា «ធុំក្លិនអាក្រក់»; បើចង់ឲ្យច្បាស់លាស់, បញ្ចូលពាក្យដទៃមកជាជំនួយក៏បាន; ដូច: it smell bod (វាធុំ, ក្លិនអាក្រក់) ។

បើប្រើចំពោះវត្ថុមានក្លិនល្អត្រូវតែបញ្ចូលពាក្យដទៃមកជាជំនួយ; ដូច: the rose smells sweet (ផ្កាកុឡាបមានក្លិនក្រអូបឬផ្អែម)

IX- TO TAKE A LOOK At;
( to look at )

មើល; សំឡឹងមើល; ក្រឡេកមើល ;

1- TAKE A LOOK AT the hat Hari is wearing to-day.

ចូរមើលមួក ដែលហារីពាក់ថ្ងៃនេះ ។

2- He TOOK A LOOK AT her and began to laugh.

គាត់បានក្រឡេកមើលនាង ហើយចាប់ផ្ដើមសើច ។

X- TO FALL TO;
( ta commence; to commence to eat; to become a duty. )

ចាប់ផ្ដើម(ធ្វើ) ផ្ដើមបរិភោគ; ជានាទី;

1- As soon as the work was distributed, each man FELL To..

ការដែលគេបានចែកការងាររួចហើយ បុរសម្នាក់ៗក៏បានចាប់ផ្ដើមធ្វើ ។

2- He FELL TO raveniously.

គាត់ចាប់ផ្ដើមបរិភោគយ៉ាងល្មោភ ។

3- It FELL TO me to tell him.

នោះគឺជានាទីរបស់ខ្ញុំត្រូវប្រាប់គាត់ ។

(នៅមានត)

រោងពុម្ពទវិយ

នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥